ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# ពូជដំណាំនៅកម្ពុជា



ខែធ្នូ ឆ្នាំ២០១៦

សៀវភៅនេះ ត្រូវបានបោះពុម្ពក្រោមជំនួយថវិកាពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី
ខ្សែសង្វាក់តំលៃកសិកម្មកម្ពុជា ហៅកាត់ថាកាវ៉ាក់ (CAVAC)។

Australian Aid

CAVAC Innovation in Agriculture

# មាតិកា

AIDOC
Code: 249-026
Date:
Donated by:

អារម្ភកថា .................................................................. i
១. សេចក្តីផ្តើម .................................................................. ១
១.១. ស្ថានភាពឧស្សាហកម្មពូជដំណាំ .................................................................. ៣
១.២. ឧបសគ្គ និងបញ្ហាប្រឈមចម្បងនៅក្នុងឧស្សាហកម្មពូជដំណាំ .................................................................. ៤
២. ទស្សនវិស័យ គោលបំណង និងគោលដៅ .................................................................. ៥
២.១. ទស្សនវិស័យ .................................................................. ៥
២.២. គោលបំណង .................................................................. ៥
២.៣. គោលដៅ .................................................................. ៦
៣. យុទ្ធសាស្ត្រ .................................................................. ៦
៣ .១. ការគ្រប់គ្រងឧស្សាហកម្មពូជដំណាំ .................................................................. ៦
៣.២. ការអភិវឌ្ឍប្រភេទពូជដំណាំ .................................................................. ៧
៣.៣. ការពិសោធ និងការចុះបញ្ជីប្រភេទពូជដំណាំ .................................................................. ៨
៣.៤. ការការពារប្រភេទពូជថ្មីនៃដំណាំ .................................................................. ៩
៣.៥. ពូជបម្លែងពន្ធុ (GMO) .................................................................. ១០
៣.៦. ផលិតកម្ម និងការផ្គត់ផ្គង់ពូជដំណាំ .................................................................. ១០
៣.៧. ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ .................................................................. ១៤
៣.៨. ការនាំចូល និងនាំចេញពូជដំណាំ .................................................................. ១៥
៣.៩. បទដ្ឋានគតិយុត្តិនៅក្នុងឧស្សាហកម្មពូជដំណាំ .................................................................. ១៦
៣.១០. ហិរញ្ញប្បទានក្នុងឧស្សាហកម្មពូជដំណាំ .................................................................. ១៧
៣.១១. ការពិចារណាដល់បរិស្ថាន .................................................................. ១៨
៣.១២. សហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ .................................................................. ១៩
៤. សកម្មភាពជាអាទិភាព .................................................................. ១៩
៥. ការត្រួតពិនិត្យ និងវាយតម្លៃ .................................................................. ២១
៦. សន្និដ្ឋាន .................................................................. ២១
៧. វាក្យស័ព្ទ .................................................................. ២២



# អារម្ភកថា

បច្ចុប្បន្នវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា កំពុងស្ថិតនៅក្នុងស្ថានភាពអភិវឌ្ឍន៍មួយ ដែលកំពុងកែប្រែពីផលិតកម្មកសិកម្មគ្រួសារតាមបែបរិបុលកម្ម ពឹងផ្អែកសំខាន់លើធនធានធម្មជាតិដែលមានស្រាប់ និងការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មី ផ្តោតទៅលើរូបភាពផលិតកម្មកសិកម្មតាមបែបប្រពលវប្បកម្ម ដោយផ្អែកសំខាន់លើការអនុវត្តបច្ចេកវិទ្យាទំនើបនៅក្នុងគ្រប់ដំណាក់កាលនៃខ្សែសង្វាក់ផលិតកម្មកសិកម្ម ។ ជារួមដំណាក់កាលនៃការអភិវឌ្ឍវិស័យកសិកម្មបាននិងកំពុងឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះចក្ខុវិស័យនៃគោលនយោបាយវិស័យកសិកម្ម ដែលក្នុងនោះរាជរដ្ឋាភិបាលបានកំណត់គោលដៅជាយុទ្ធសាស្ត្រ គឺការលើកកម្ពស់ផលិតភាពកសិកម្ម ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម តាមរយៈការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ដោយផ្តោតលើអន្តរាគមន៍ប្រទាក់ក្រឡាជាក់លាក់រវាងអន្តរវិស័យពាក់ព័ន្ធ។ កិច្ចអន្តរាគមន៍គន្លឹះរួមមានការផ្តល់ប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម ការប្រើធាតុចូលកសិកម្មតាមបច្ចេកទេស ការស្រាវជ្រាវកសិកម្ម និងយន្តូបនីយកម្មកសិកម្ម ការសាងសង់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ការអភិវឌ្ឍធារាសាស្ត្រ និងប្រព័ន្ធស្រោចស្រព ការផ្គត់ផ្គង់ថាមពលអគ្គិសនី ការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន ទីផ្សារ ការផ្តល់ឥណទានជនបទនិងមីក្រូហិរញ្ញវត្ថុ ការពង្រីកទីផ្សារផលិតផលកសិកម្ម ការរៀបចំសហគមន៍កសិកម្ម ការគ្រប់គ្រងដីកសិកម្ម និងយន្តការសម្របសម្រួលស្ថាប័នជាដើម។ ជាក់ស្តែង គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ បានឆ្លុះបញ្ចាំងឱ្យឃើញនូវកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចជោគជ័យតាមគោលបំណងខាងលើនេះ ដោយបានជំរុញការអនុវត្តវិធានការពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព ដោយចាប់ផ្តើមពីការងារអភិវឌ្ឍនៅក្នុងផលិតកម្មដំណាំស្រូវ ជាពិសេសការស្រាវជ្រាវ និងការផ្សព្វផ្សាយពូជស្រូវប្រកបដោយគុណភាព និងមានតម្លៃទីផ្សារ ការប្រមូលទិញស្រូវ និងការអភិវឌ្ឍផលិតកម្មកែច្នៃអង្ករ ការទ្រទ្រង់ឥណទានស្រូវអង្ករ ការរៀបចំប្រព័ន្ធសម្រួលពាណិជ្ជកម្ម ការស្វែងរកទីផ្សារ ការប្រកួតប្រជែងគុណភាពអង្ករលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ ។ល។

ឆ្លងកាត់ដំណាក់កាលនៃការផ្លាស់ប្តូរខាងលើ បាននាំមកនូវចំណេះដឹងថ្មីចំពោះអ្នកដាំដុះ ដែលកំពុងមានចំណាប់អារម្មណ៍ខ្ពស់អំពីគុណភាពពូជដំណាំ ក្នុងនោះការប្រើប្រាស់ពូជដំណាំមានគុណភាពល្អ គឺជាកត្តាចម្បងសម្រាប់បង្កើនទិន្នផលនៃផលិតកម្មកសិកម្ម និងធានាបាននូវគុណភាពផលិតផលរបស់ខ្លួន។ ករណីនេះបានបញ្ជាក់ថា ពូជដំណាំគឺជាចំណុចចាប់ផ្តើមនៃខ្សែសង្វាក់ផលិតកម្ម និងជាធាតុចូលដ៏សំខាន់ដែលជួយជំរុញឱ្យកសិករ និងអ្នកដាំដុះផ្សេងទៀតទទួលបានទិន្នផលកសិផលខ្ពស់ប្រកបដោយគុណភាពនៅក្នុងពេលប្រមូលផល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសិក្សារៀបចំគោលនយោបាយពូជដំណាំនេះ នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល



ក្នុងបរិបទនៃការធានាសុវត្ថិភាព គុណភាព ផលិតភាពស្បៀង និងការបង្កើនផលិតភាពកសិកម្ម និងមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទផងដែរ។ គោលនយោបាយនេះ ត្រូវបានរៀបចំក្នុងក្របខណ្ឌនៃទស្សនវិស័យការអភិវឌ្ឍឧស្សាហកម្មពូជដំណាំរយៈពេលវែង ដែលចាំបាច់ត្រូវអនុវត្តរួមគ្នាជាមួយនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ហើយជាយន្តការគ្រប់ជ្រុងជ្រោយដែលអាចឆ្លើយតបតាមសេចក្តីត្រូវការរបស់គ្រប់ភាគីពាក់ព័ន្ធ ស្របតាមបរិបទនៃការប្រែប្រួលអាកាសធាតុ និងការវិវត្តនៃទីផ្សារផលិតផលកសិកម្មក្នុងតំបន់ និងអន្តរជាតិ និងអាចបំពេញបាននូវសេចក្តីត្រូវការរបស់កសិករ និងអ្នកដាំដុះផ្សេងទៀតនៅក្នុងផលិតកម្មកសិកម្ម ប្រកបដោយប្រសិទ្ធផលខ្ពស់។ គោលដៅចម្បងមួយទៀតនៃគោលនយោបាយនេះ គឺធានាឱ្យអ្នកដាំដុះអាចទទួលបានពូជដំណាំប្រកបដោយគុណភាពខ្ពស់ និងប្រភេទពូជបសិដ្ឋកម្មទាំងឡាយតាមរយៈបណ្តាញផ្គត់ផ្គង់ប្រកបដោយភាពទុកចិត្ត និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់បំផុត។ ដើម្បីសម្រេចបានគោលដៅនេះ ជាចាំបាច់ត្រូវបង្កបរិយាកាសអំណោយផលសម្រាប់ការវិនិយោគរបស់ផ្នែកឯកជននៅក្នុងការអភិវឌ្ឍឧស្សាហកម្មពូជដំណាំតាមបែបពាណិជ្ជកម្មចម្រុះ ដែលផ្តល់ផលប្រយោជន៍ចំពោះកសិករ និងអ្នកដាំដុះផ្សេងទៀតនូវលទ្ធភាពជ្រើសរើសទាំងពូជដំណាំដែលមានគុណភាពល្អ និងប្រភេទពូជបសិដ្ឋកម្មល្អៗ ដែលមានប្រភពផ្គត់ផ្គង់គួរឱ្យទុកចិត្តបាន។

សេចក្តីព្រាងលើកទីមួយនៃគោលនយោបាយពូជដំណាំនៅកម្ពុជា ត្រូវបានរៀបចំនៅឆ្នាំ២០១១ ដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយគម្រោងស្បៀងអាហាររបស់សហភាពអឺរ៉ុបដែលអនុវត្តដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។ នៅក្នុងអំឡុងឆ្នាំ២០១២ សេចក្តីព្រាងនេះត្រូវបានកែសម្រួលជាបន្តបន្ទាប់បន្ថែមទៀតដោយក្រុមការងារបច្ចេកទេសនៃអគ្គនាយកដ្ឋានកសិកម្ម ក្រោមជំនួយហិរញ្ញប្បទានរបស់កម្មវិធីហាវេសត៍ នៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។នៅក្នុងដំណើរការកែសម្រួលសេចក្តីព្រាងគោលនយោបាយនេះត្រូវបានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់ចំនួនពីរលើក ដោយមានការចូលរួមពីសំណាក់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ស្ថាប័នបណ្តុះបណ្តាល និងស្រាវជ្រាវកសិកម្ម ក្រុមហ៊ុនផលិតពូជដំណាំ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ មតិយោបល់ និងអនុសាសន៍ដែលបានលើកឡើងដោយសិក្ខាសាលាពិគ្រោះយោបល់ខាងលើ ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងលើកទី២នាឆ្នាំ២០១៣។ ដោយមានការគាំទ្រតាមរយៈជំនួយហិរញ្ញប្បទានពីកម្មវិធីអភិវឌ្ឍវិស័យពាណិជ្ជកម្មដំណាំស្រូវធន់នឹងបម្រែបម្រួលអាកាសធាតុរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងដោយមានការចូលរួមវិភាគទានយ៉ាងសកម្មជាថ្មីម្តងទៀតពីអង្គភាពជំនាញពាក់ព័ន្ធ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធផ្សេងទៀត ការរៀបចំគោលនយោបាយពូជដំណាំនៅកម្ពុជា ត្រូវបានបញ្ចប់ជាស្ថាពរនៅខែតុលា ឆ្នាំ២០១៦។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសុឆន្ទៈ និងការតាំងចិត្តយ៉ាងមុតមាំ ក្នុងការដឹកនាំការអនុវត្តគោលនយោបាយនេះ និងសូមអំពាវនាវ ព្រមទាំងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធ រួមមាន វិស័យ

សាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ កសិករ និងសហគមន៍អ្នកដាំដុះ ដើម្បីរួមគ្នាគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយនេះឱ្យទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម ការរក្សាកំណើនសេដ្ឋកិច្ចជាតិ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងការរួមចំណែកសម្រេចគោលដៅកំណែទម្រង់ដើម្បីចីរភាពនៃការអភិវឌ្ឍក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# ១. សេចក្តីផ្តើម

១.រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ពីសារៈសំខាន់របស់វិស័យកសិកម្មក្នុងការធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ស្រូវជាដំណាំសំខាន់មួយសម្រាប់សេដ្ឋកិច្ចជនបទ ហើយរាជរដ្ឋាភិបាលបានបង្ហាញពីជំហរគាំទ្រលើផលិតកម្មដំណាំនេះ តាមរយៈគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករនៅឆ្នាំ២០១០។ ផលិតកម្មដំណាំស្រូវ និងការនាំចេញអង្ករមានសន្ទុះកើនឡើងជាបន្តបន្ទាប់នៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយ បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយខាងលើ ទោះបីជាសន្ទស្សន៍នាំចេញអង្ករជាក់ស្តែងមិនទាន់បានឆ្លើយតបនឹងសូចនាករកំណត់ក្តី។ កម្ពុជាបានទាញយកផលប្រយោជន៍ក្នុងនាមជាអ្នកនាំចេញគ្រាប់ធញ្ញជាតិក្នុងអំឡុងពេលដែលក្តីបារម្ភអំពីការផ្គត់ផ្គង់ស្បៀងអាហារនៅក្នុងពិភពលោកកំពុងកើនឡើង។ ការរក្សា និងពង្រឹងដំណែងនេះមានសារៈសំខាន់ណាស់សម្រាប់សន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ច។

២.ការប្រើប្រាស់ពូជដំណាំមានគុណភាពល្អ គឺជាកត្តាសំខាន់បំផុតមួយសម្រាប់បង្កើនទិន្នផលក្នុងផលិតកម្មកសិកម្ម ហើយអាចផ្តល់ប្រយោជន៍យ៉ាងច្រើនដល់កសិករ និងអ្នកដាំដុះផ្សេងទៀតទាំងកសិកម្មខ្នាតតូច និងខ្នាតធំ។ ពូជដំណាំគឺជាធាតុចូលសំខាន់មួយសម្រាប់ផ្សព្វផ្សាយប្រភេទពូជថ្មីដល់កសិករ ដើម្បីលើកកម្ពស់ផលិតផលកសិកម្មទាំងបរិមាណនិងគុណភាព ដែលនាំមកនូវកំណើនប្រាក់ចំណូល។ លើសពីនេះទៅទៀត ផលិតកម្ម និងទីផ្សារពូជដំណាំ អាចផ្តល់ឱកាសក្នុងការពង្រីកមុខរបរខ្នាតតូចនៅតំបន់ជនបទផងដែរ។

៣.ដោយកសិករ និងអ្នកដាំដុះផ្សេងទៀត បានចាប់ផ្តើមផ្លាស់ប្តូរទម្លាប់ពីផលិតកម្មបែបគ្រួសារទៅជាផលិតកម្មបែបពាណិជ្ជកម្មសម្រាប់ផ្គត់ផ្គង់ទីផ្សារនោះ អ្នកដាំដុះមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងអំពីគុណភាពពូជដំណាំដែលត្រូវយកមកប្រើប្រាស់។ នៅក្នុងផលិតកម្មដំណាំស្រូវ កង្វះគ្រាប់ពូជសុទ្ធដែលមានគុណភាពល្អ គឺជាឧបសគ្គមួយក្នុងការជំរុញឱ្យមានឯកសណ្ឋានភាពនៃផលិតផលដែលរោងម៉ាស៊ីនកិនស្រូវត្រូវទទួលយកទៅកែច្នៃ។ ករណីនេះបញ្ជាក់ថា ពូជដំណាំគឺជាចំណុចចាប់ផ្តើមសំខាន់បំផុតនៃខ្សែសង្វាក់ផលិតកម្ម។ ដូច្នេះការបង្កើនគុណភាពផលិតផលរបស់អ្នកដាំដុះ ត្រូវតែចាប់ផ្តើមពីពូជដំណាំមានគុណភាពដែលត្រូវយកទៅដាំដុះ។ បញ្ហាគ្រាប់ដំណាំនៅក្នុងផលិតកម្មដំណាំផ្សេងទៀត ក៏មានលក្ខណៈដូចគ្នាទៅនឹងករណីដែលមាននៅក្នុងដំណាំស្រូវផងដែរ ដោយហេតុថា គុណភាពនៃផលិតផលគឺជាការតម្រូវដ៏ចាំបាច់សម្រាប់លក់ និងចែកចាយនៅក្នុងប្រព័ន្ធទីផ្សារដែលមានការផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការប្រើប្រាស់ពូជដំណាំមានគុណភាពល្អ។

៤. ច្បាប់ស្តីពី "ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ" ដែលបានចូលជាធរមាននៅខែមេសា ឆ្នាំ២០០៨ បានផ្តល់នូវបទដ្ឋានគតិយុត្តិជាមូលដ្ឋាននៅក្នុងការធ្វើពាណិជ្ជកម្មពូជដំណាំ និងការការពារសិទ្ធិអ្នកបង្កាត់ពូជ។ បន្ទាប់មក អនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៨ បានប្រគល់ភារកិច្ច និងការទទួលខុសត្រូវលើការគ្រប់គ្រងពូជដំណាំដល់អគ្គនាយកដ្ឋានកសិកម្ម។ ដូច្នេះអគ្គនាយកដ្ឋានកសិកម្មមានតួនាទីអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំនេះ តាមរយៈបទដ្ឋានគតិយុត្តនានាឱ្យមានប្រសិទ្ធភាពខ្ពស់។

៥. ទោះបីគ្រាប់ពូជស្រូវទទួលបាននូវអាទិភាពក្នុងចំណោមពូជដំណាំផ្សេងទៀត នៅក្នុងផលិតកម្មកសិកម្ម និងក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចក្តី គ្រាប់ពូជ និងសរីរាង្គដាំដុះនៃដំណាំផ្សេងទៀត ក៏ត្រូវស្ថិតនៅក្រោមវិសាលភាពរបស់គោលនយោបាយនេះផងដែរ។ ឯកសារនេះគ្របដណ្តប់លើគ្រប់ផ្នែកនៃខ្សែសង្វាក់ផលិតកម្ម និងផ្គត់ផ្គង់ពូជដំណាំ ចាប់តាំងពីការបង្កាត់ពូជ ការណែនាំពូជថ្មី រហូតដល់ការផលិតការបញ្ចេញ ការលក់ចែកចាយ និងការប្រើប្រាស់ពូជដំណាំ។ គោលនយោបាយនេះ ក៏ឆ្លុះបញ្ចាំងផងដែរអំពីសេចក្តីត្រូវការរបស់អាជីវករកែច្នៃ អ្នកនាំចេញ និងអតិថិជនក្នុងស្រុក ដែលមានគោលបំណងចូលរួមដោះស្រាយបញ្ហាផ្សេងៗនៅក្នុងប្រព័ន្ធផ្គត់ផ្គង់ពូជដំណាំ ផ្អែកតាមបញ្ហាជាក់លាក់ដែលកើតឡើង និងសេចក្តីត្រូវការជាក់ស្តែង។

៦. ការរៀបចំគោលនយោបាយពូជដំណាំនៅកម្ពុជានេះ ស្ថិតនៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងបរិបទនៃការធានាសន្តិសុខស្បៀង និងការបង្កើនផលិតភាពកសិកម្ម។ គោលនយោបាយនេះ ជាមួយនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ គឺជាយន្តការមួយដែលចាំបាច់ត្រូវអនុវត្តរួមគ្នា សម្រាប់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់កសិករ និងអ្នកដាំដុះផ្សេងទៀតនៅក្នុងផលិតកម្មកសិកម្ម។ គោលនយោបាយនេះ មានសង្គតិភាពជាមួយនឹងឯកសារយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។

៧. គោលដៅចម្បងនៃគោលនយោបាយនេះ គឺធានាឱ្យកសិករ និងអ្នកដាំដុះផ្សេងទៀតទទួលបានពូជដំណាំមានគុណភាពខ្ពស់ និងប្រភេទពូជល្អតាមរយៈបណ្តាញផ្គត់ផ្គង់ប្រកបដោយភាពទុកចិត្ត និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់បំផុត។ ដើម្បីសម្រេចបានគោលដៅនេះ ជាចាំបាច់ត្រូវបង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំតាមបែបពាណិជ្ជកម្មចម្រុះ ដែលផ្តល់ឱ្យកសិករ និងអ្នកដាំដុះផ្សេងទៀត នូវលទ្ធភាពជ្រើសរើសទាំងពូជដំណាំដែលមានគុណភាពល្អ និងប្រភេទពូជបសិដ្ឋកម្ម

សមស្រប និងប្រភពផ្គត់ផ្គង់ដែលមានទំនុកចិត្តដើម្បីទទួលបានពូជដំណាំល្អសម្រាប់ប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលផលិតភាពដីឱ្យបានពេញលេញ។

## ១.១. ស្ថានភាពឧស្សាហកម្មពូជដំណាំ

៨. ការវិនិយោគចម្បងក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវជាលើកដំបូងដែលបានអនុវត្តដោយអតីតនាយកដ្ឋានក្សេត្រសាស្ត្រ ក្នុងកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (IRRI) ដែលគាំទ្រថវិកាដោយប្រទេសអូស្ត្រាលី បានបង្កើតជាគម្រោងអភិវឌ្ឍន៍ដំណាំស្រូវ ដែលហៅថា គម្រោងកម្ពុជា-អ៊ីរី-អូស្ត្រាលី (CIAP) ដែលនេះជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតជាវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានៅក្នុងឆ្នាំ១៩៩៩។ អាស្រ័យដោយមានមូលដ្ឋានស្រាវជ្រាវថ្នាក់ជាតិនេះ ប្រភេទពូជស្រូវជាច្រើនត្រូវបានបញ្ចេញឱ្យប្រើប្រាស់។ ប៉ុន្តែការរៀបចំប្រព័ន្ធផលិតកម្មគ្រាប់ពូជស្រូវដែលមានលក្ខណៈពាណិជ្ជកម្មសម្រាប់ផ្តល់ដល់កសិករ និងអ្នកដាំដុះផ្សេងទៀតនូវពូជស្រូវទាំងនោះ តាមរយៈការផ្គត់ផ្គង់គ្រាប់ពូជដែលមានគុណភាព នៅមិនទាន់មានឡើយ។ ដើម្បីបំពេញភាពខ្វះចន្លោះនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់គ្រាប់ពូជនេះ ភ្នាក់ងារជំនួយអភិវឌ្ឍរបស់អូស្ត្រាលី (AusAID) បានរៀបចំឱ្យមានគម្រោងបង្កើនគុណភាពកសិកម្ម (AQIP) នៅឆ្នាំ១៩៩៧ ដែលក្នុងនោះផលិតកម្ម និងការផ្គត់ផ្គង់គ្រាប់ពូជស្រូវគឺជាសមាសភាគចម្បងរបស់គម្រោង។ គម្រោងបានបង្កើតឱ្យមានក្រុមហ៊ុនផលិតគ្រាប់ពូជថ្នាក់តំបន់ចំនួនបួន ប៉ុន្តែនៅពេលដែលគម្រោងបានត្រូវបញ្ចប់នៅឆ្នាំ២០០៧ ក្រុមហ៊ុនទាំងអស់ត្រូវបានរួមបញ្ចូលជាក្រុមហ៊ុនតែមួយហៅថា អេគីបស៊ីដ (AQIP Seed) ដែលជាក្រុមហ៊ុនផលិតគ្រាប់ពូជស្រូវថ្នាក់ជាតិតែមួយគត់នៅកម្ពុជា ដោយធ្វើអាជីវកម្មតែលើគ្រាប់ពូជស្រូវប៉ុណ្ណោះ។

៩. ក្នុងរយៈពេលជាងម្ភៃឆ្នាំកន្លងមក គម្រោងរបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានគាំទ្រដល់ការផ្តួចផ្តើមក្នុងមូលដ្ឋាន និងសហគមន៍តាមបណ្តាខេត្តនានា ដោយផ្តោតលើការចងក្រងក្រុមកសិករផលិតពូជដំណាំ និងការបណ្តុះបណ្តាលបច្ចេកទេសជំនាញផលិតកម្មពូជដំណាំ។ គម្រោងមួយចំនួនបានបំពេញការងារល្អក្នុងអំឡុងពេលអនុវត្ត ប៉ុន្តែគម្រោងទាំងនោះជាញឹកញាប់ពុំមានផែនការហិរញ្ញវត្ថុឬទីផ្សារច្បាស់លាស់ ដែលជាហេតុធ្វើឱ្យសកម្មភាពរបស់គម្រោងទាំងនោះពុំមាននិរន្តរភាពក្រោយពេលបញ្ចប់។ ករណីនេះ បើទោះបីជាមានអន្តរាគមន៍ឬមានបទពិសោធន៍ខ្ពស់យ៉ាងណាក្តី ក៏ឧស្សាហកម្មពូជដំណាំនៅតែពុំទាន់មានការសម្របសម្រួលបានល្អ និងពុំទាន់មានជំហររឹងមាំក្នុងការបោះជំហានឆ្ពោះទៅរកបែបផែនពាណិជ្ជកម្មទូលំទូលាយ។ ស្ថានភាពនេះគឺជាកត្តាគន្លឹះដ៏សំខាន់មួយដែលត្រូវបញ្ចូលទៅក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីជំរុញការផ្លាស់ប្តូរអន្តរកាលនេះនៅក្នុងការពង្រឹងផលិតកម្មកសិកម្ម និងបង្កើនការនាំចេញអង្ករដែលមានគុណភាពខ្ពស់។

១០. ពូជដំណាំផ្សេងទៀត ដូចជាដំណាំពោត និងបន្លែជាដើម ភាគច្រើនត្រូវបាននាំចូលមកពីប្រទេសវៀតណាម ប្រទេសថៃ ឬពីប្រទេសដទៃទៀត ដែលនៅក្នុងប្រទេសទាំងនោះ មានក្រុមហ៊ុនឯកជន

ធំៗ រួមជាមួយនឹងកម្មវិធីជម្រើសពូជច្បាស់លាស់។ នៅក្នុងរយៈពេលខ្លីចំពោះមុខ ព្រះរាជាណាចក្រកម្ពុជាអាចនឹងជួបការលំបាកក្នុងការផលិត និងចែកចាយពូជដំណាំ ដែលមានស្តង់ដារគុណភាពដូចគ្នានឹងពូជដំណាំនាំចូល។ ដូច្នេះសម្រាប់ពូជដំណាំទាំងនេះ ត្រូវមានការពង្រឹងលើប្រព័ន្ធវាយតម្លៃនិងការចុះបញ្ជីប្រភេទពូជដំណាំដែលអាចមានប្រយោជន៍ដល់កសិករ និងអ្នកដាំដុះផ្សេងទៀត ទន្ទឹមគ្នានឹងការខិតខំអភិវឌ្ឍ ផលិត និងចែកចាយពូជដំណាំក្នុងស្រុក ។

## ១.២. ឧបសគ្គ និងបញ្ហាប្រឈមចម្បងនៅក្នុងឧស្សាហកម្មពូជដំណាំ

១១. តាមរយៈការប្រឹក្សាយោបល់ជាមួយបណ្តាភាគីពាក់ព័ន្ធ បញ្ហាចម្បងមួយចំនួនដែលជាកត្តាគន្លឹះ និងធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំប្រកបដោយប្រសិទ្ធភាពនៅកម្ពុជាមានដូចខាងក្រោម៖

- ការខ្វះចន្លោះក្នុងការចែកចាយព័ត៌មានបច្ចេកទេស និងមានការយល់ដឹងតិចតួចស្តីពីតម្លៃ និងផលប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់ពូជដំណាំដែលមានគុណភាពល្អ
- ស្តង់ដារគុណភាពពូជដំណាំ និងប្រព័ន្ធផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ នៅមិនទាន់បានអភិវឌ្ឍ ឬមិនទាន់បានដាក់ឱ្យដំណើរការអនុវត្តនៅឡើយ
- កង្វះតម្លាភាពនៅក្នុងការនាំចូល និងនីតិវិធីចុះបញ្ជី ធ្វើឱ្យកើតមាននូវពាណិជ្ជកម្មមិនផ្លូវការជាច្រើនដែលមានព័ត៌មានតិចតួចបំផុតស្តីពីគុណភាពនៃពូជដំណាំនាំចូល។

ដោយឡែក នៅក្នុងបរិបទនៃគ្រាប់ពូជស្រូវមានជួបបញ្ហាសំខាន់ៗដូចខាងក្រោម៖

- មានការលំបាកក្នុងការធ្វើផែនការផលិតកម្មគ្រាប់ពូជស្រូវ ដោយសារតែភាពមិនច្បាស់លាស់អំពីតម្រូវការរបស់អ្នកដាំដុះ និងទីផ្សារ
- ការយល់ដឹងអំពីប្រភេទពូជ និងតម្រូវការនៅក្នុងទីផ្សារនៅមានកម្រិតទាប ដែលជាមូលហេតុបណ្តាល ឱ្យអង្ករគុណភាពល្អ ត្រូវបានលក់ជាអង្ករចម្រុះក្នុងតម្លៃទាបនៅលើទីផ្សារ
- មិនមានការបែងចែកច្បាស់លាស់រវាងស្រូវចំណី និងគ្រាប់ពូជ ដែលជាហេតុធ្វើឱ្យកសិករ និងអ្នកដាំដុះផ្សេងទៀត មានភាពស្ទាក់ស្ទើរនៅក្នុងការទិញគ្រាប់ពូជដែលមានតម្លៃថ្លៃជាងស្រូវចំណី
- ទទួលបានផលប្រយោជន៍តិចតួចពីការប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ ដោយសារតែភាពទន់ខ្សោយនៃខ្សែសង្វាក់ក្រោយពេលប្រមូលផល។

១២. បញ្ហាគន្លឹះមួយដែលមាននៅក្នុងឧស្សាហកម្មគ្រាប់ពូជស្រូវនៅកម្ពុជា គឺផលិតកម្ម និងពាណិជ្ជកម្មគ្រាប់ពូជស្រូវ ទទួលបានប្រាក់ចំណេញទាប។ ដូច្នេះទើបគ្មានការទាក់ទាញវិនិយោគទុនឯកជន បើទោះបីជាគ្រាប់ពូជស្រូវមានគុណភាពល្អ ជាធាតុចូលដ៏សំខាន់ក្នុងផលិតកម្មដំណាំស្រូវក៏ដោយ។ ដើម្បីដោះស្រាយបញ្ហានេះ ការវិនិយោគលើផលិតកម្មគ្រាប់ពូជស្រូវនៅក្នុងទ្រង់ទ្រាយធំដោយវិស័យសាធារណៈ

ត្រូវប្រឈមនឹងការលំបាកក្នុងការគ្រប់គ្រង ហើយជាញឹកញាប់គឺមានបញ្ហាពាក់ពន្ធ័នឹងហិរញ្ញវត្ថុ។ ដូច្នេះ កត្តាចាំបាច់ត្រូវរៀបចំយ៉ាងណាឱ្យប្រព័ន្ធផ្គត់ផ្គង់គ្រាប់ពូជស្រូវឆ្លើយតបនឹងសេចក្តីត្រូវការរបស់កសិករ និងអ្នកដាំដុះផ្សេងទៀត ប្រកបដោយនិរន្តរភាពដោយពុំតម្រូវឱ្យមានការឧបត្ថម្ភធនឡើយ។

១៣. ចំពោះផលិតកម្ម និងទីផ្សារពូជដំណាំដទៃទៀត ជាពិសេសពូជពោតអ៊ីប្រ៊ីត គឺអាចទទួលបាននូវប្រាក់ចំណេញខ្ពស់ ហើយត្រូវបានយកចិត្តទុកដាក់ដោយវិស័យឯកជន។ ទោះជាយ៉ាងណាក៏ដោយ ដំណាំនីមួយៗ មានបញ្ហាជាក់លាក់រៀងខ្លួននៅក្នុងដំណើរការផលិត និងការផ្គត់ផ្គង់ពូជដំណាំ។ គោលនយោបាយនេះ មានគោលបំណងដោះស្រាយនូវរាល់បញ្ហា តាមរយៈកិច្ចពិភាក្សា និងសម្របសម្រួលរវាងអ្នកបច្ចេកទេស និងតួអង្គពាក់ព័ន្ធ ដើម្បីធានាថាកសិករនិងអ្នកដាំដុះផ្សេងទៀត អាចទទួលបាននូវប្រភេទពូជល្អៗ និងពូជដំណាំដែលមានគុណភាពសម្រាប់យកទៅដាំដុះ។

១៤. តាមការវិភាគខាងលើបានបង្ហាញយ៉ាងច្បាស់ថា ឧស្សាហកម្មពូជដំណាំនៅកម្ពុជាស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដែលចាំបាច់ទាមទារឱ្យមានការគាំទ្រ និងវិនិយោគបន្ថែមទៀត។ ប៉ុន្តែឧបសគ្គដែលបានរៀបរាប់មិនទាក់ទងនឹងបញ្ហាបច្ចេកទេសជាចម្បងឡើយ ភាគច្រើនទាក់ទងទៅនឹងកត្តាហិរញ្ញវត្ថុ រចនាសម្ព័ន្ធចាត់តាំង និងក្របខណ្ឌគតិយុត្ត។ បញ្ហាទាំងនេះ អាចដោះស្រាយបាន តាមរយៈការអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពទាក់ទិននឹងទិដ្ឋភាពបច្ចេកទេសជាក់លាក់ដើម្បីលើកកម្ពស់គុណភាពពូជដំណាំ ដែលបានកំណត់នៅក្នុងគោលនយោបាយនេះ រួមជាមួយនឹងការគាំទ្រដោយច្បាប់ និងបទដ្ឋានគតិយុត្ត ។

## ២. ទស្សនវិស័យ គោលបំណង និងគោលដៅ

### ២.១. ទស្សនវិស័យ

១៥. បង្កើតបាននូវឧស្សាហកម្មពូជដំណាំមួយដែលមាននិរន្តភាព និងមានប្រសិទ្ធភាពខ្ពស់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កសិករ និងអ្នកដាំដុះផ្សេងទៀត មិនត្រឹមតែសម្រាប់សន្តិសុខស្បៀងប៉ុណ្ណោះទេ តែជាមូលដ្ឋានដែលអាចនាំមកនូវអតិរេកនៃផលិតផលកសិកម្មប្រកបដោយគុណភាព និងសុវត្ថិភាពខ្ពស់ សម្រាប់ការនាំចេញ ដែលរួមចំណែកលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ចជាតិ។

### ២.២. គោលបំណង

១៦. ធានាថាកសិករ និងអ្នកដាំដុះផ្សេងទៀត ទទួលបានពូជដំណាំដែលមានគុណភាពខ្ពស់ និងប្រភេទពូជល្អៗ ដែលអាចសម្រេចបានដោយពេញលេញនូវសក្តានុពលនៃផលិតភាពកសិកម្ម តាមរយៈបណ្តាញផ្គត់ផ្គង់ប្រកបដោយភាពទុកចិត្ត និងមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។

## ២.៣. គោលដៅ

១៧. ដើម្បីសម្រេចបាននូវទស្សនវិស័យ និងគោលបំណងខាងលើ គោលនយោបាយនេះមានគោលដៅ៖

- បង្កើនប្រសិទ្ធភាពរបស់ស្ថាប័ន និងបង្កើតប្រព័ន្ធគ្រប់គ្រងពូជដំណាំនៅគ្រប់ថ្នាក់ ដើម្បីឱ្យមានការគ្រប់គ្រង និងការសម្របសម្រួលល្អ តាមរយៈកិច្ចសហការល្អរវាងអ្នកពាក់ព័ន្ធទាំងឡាយ
- បង្កើតការត្រួតពិនិត្យជាផ្លូវការ និងនីតិវិធីសម្រាប់គ្រប់គ្រងពូជដំណាំ ដែលមានសង្គតភាពនឹងបណ្ដាប្រទេសដទៃទៀតនៅក្នុងតំបន់ ដើម្បីសម្របសម្រួលឱ្យមានភាពរលូននៅក្នុងការធ្វើពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍អាស៊ាន
- ពង្រឹងការទទួលខុសត្រូវលើការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័នសាធារណៈ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងៗទៀត
- បង្កើនការយល់ដឹងរបស់អ្នកដាំដុះ ជាពិសេសប្រជាកសិករ អំពីផលប្រយោជន៍នៃការប្រើប្រាស់ពូជបសិដ្ឋកម្ម និងពូជដំណាំដែលមានគុណភាពល្អតាមរយៈការផ្សព្វផ្សាយ និងការធ្វើបង្ហាញ
- ពង្រឹងសមត្ថភាពរបស់ក្រុមផលិតពូជដំណាំឱ្យឆ្លើយតបនឹងសេចក្ដីត្រូវការក្នុងមូលដ្ឋាន និងតម្រូវការនៃទីផ្សារនាំចេញ
- អភិវឌ្ឍបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ផ្ដល់វិញ្ញាបនបត្រ ព្រមទាំងអធិការកិច្ចពូជដំណាំ ដើម្បីធានាថា ពូជដំណាំដែលមានគុណភាពល្អ ត្រូវបានចែកចាយដល់កសិករ និងអ្នកដាំដុះផ្សេងទៀត
- ជំរុញការវិនិយោគរបស់ស្ថាប័នសាធារណៈ និងវិស័យឯកជន ដើម្បីពង្រឹងវិស័យគ្រាប់ពូជប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។

# ៣. យុទ្ធសាស្ត្រ

១៨. ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ត្រូវផ្អែកលើយន្តការប្រទាក់ក្រឡាគ្នារវាងតួអង្គពាក់ព័ន្ធសំខាន់ចំនួនប្រាំគឺ អ្នកស្រាវជ្រាវ អ្នកផលិត អ្នកធ្វើពាណិជ្ជកម្ម អ្នកត្រួតពិនិត្យគុណភាព និងអ្នកប្រើប្រាស់។ យន្តការនេះ រួមមាន រចនាសម្ព័ន្ធ និងអង្គការចាត់តាំង ច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់ បទដ្ឋានបច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងនៃការអភិវឌ្ឍឧស្សាហកម្មពូជដំណាំប្រកបដោយនិរន្តរភាព យុទ្ធសាស្ត្រពូជដំណាំត្រូវបានកំណត់ដូចខាងក្រោម៖

## ៣.១. ការគ្រប់គ្រងឧស្សាហកម្មពូជដំណាំ

១៩. ច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បានផ្ដល់ជាមូលដ្ឋាននូវឧបករណ៍គតិយុត្តសម្រាប់គ្រប់គ្រងឧស្សាហកម្មពូជដំណាំ ដែលមានអគ្គនាយកដ្ឋានកសិកម្មជាអង្គភាពទទួលបន្ទុកអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់។ ដើម្បីធានាឱ្យមានកិច្ចសហការល្អសម្រាប់

ការគ្រប់គ្រងរាល់ពូជដំណាំទាំងអស់ អគ្គនាយកដ្ឋានកសិកម្មត្រូវបង្កើតអង្គភាពគ្រប់គ្រងពូជដំណាំ (Seed Management Unit) ដែលត្រូវគ្រប់គ្រងរាល់សកម្មភាពអាជីវកម្មពូជដំណាំ ការធ្វើវិញ្ញាបនកម្មបញ្ជាក់គុណភាពពូជដំណាំ ជាអង្គភាពទទួលបន្ទុកអនុវត្តច្បាប់ និងជាអង្គភាពបង្គោលសម្រាប់រាល់សកម្មភាព និងព័ត៌មាននានាទាក់ទងនឹងពូជដំណាំ។

**២០.** ការគ្រប់គ្រងពូជត្រូវបានរួមបញ្ចូលនូវសកម្មភាពជាច្រើន ដែលចាប់ផ្ដើមពីការពិសោធស្រាវជ្រាវ ការអភិវឌ្ឍ ការបញ្ចេញ និងការផលិតពូជដំណាំរហូតដល់ការដាំដុះ។ មានអ្នកពាក់ព័ន្ធជាច្រើនដែលចូលរួមដោយផ្ទាល់នៅក្នុងខ្សែសង្វាក់នេះ អាស្រ័យតាមសកម្មភាពរបស់ខ្លួន ដែលតម្រូវឱ្យមានយន្តការសម្របសម្រួលមួយដើម្បីជួយប្រមូលផ្ដុំតួអង្គដែលមានចំណាប់អារម្មណ៍ផ្សេងគ្នា មកធ្វើការជាមួយគ្នា។ ដើម្បីសម្រេចគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតក្រុមប្រឹក្សាជាតិពូជដំណាំ (National Seed Council ) ដែលមានមុខងារត្រួតពិនិត្យ និងតាមដានការអភិវឌ្ឍឧស្សាហកម្មពូជដំណាំស្របតាមគោលនយោបាយនេះ។ លក្ខន្តិកៈ សមាជិកភាព និងតួនាទីរបស់គណៈកម្មាធិការនេះ នឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អង្គភាពគ្រប់គ្រងពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវបំពេញមុខងារជាលេខាធិការដ្ឋានសម្រាប់ក្រុមប្រឹក្សាជាតិពូជដំណាំនេះ។

**២១.** រាល់ប្រតិបត្តិការក្នុងដំណើរការវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រឧស្សាហកម្មពូជដំណាំ ត្រូវអនុវត្តឱ្យមានសុខដុមនីយកម្មជាមួយគោលនយោបាយនេះ និងស្របតាមផែនការយុទ្ធសាស្ត្រផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ ដើម្បីធានាឱ្យមានកិច្ចសហការបានល្អ គម្រោងអភិវឌ្ឍន៍ជាផ្លូវការ ក្រុមហ៊ុន សហគមន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដែលធ្វើការពាក់ព័ន្ធជាមួយនឹងផលិតកម្មពូជដំណាំ ឬពាក់ព័ន្ធនឹងការផ្គត់ផ្គង់ពូជដំណាំ ត្រូវផ្ដល់របាយការណ៍សង្ខេបប្រចាំឆ្នាំ ស្ដីពីសកម្មភាពរបស់ខ្លួនជូនដល់អង្គភាពគ្រប់គ្រងពូជដំណាំ។

### ៣.២. ការអភិវឌ្ឍប្រភេទពូជដំណាំ

**២២.** ការអភិវឌ្ឍពូជបសិដ្ឋកម្មល្អៗ គឺជាភាពចាំបាច់នៅក្នុងការទ្រទ្រង់ និងការបង្កើនផលិតភាពកសិកម្ម ជាពិសេសសម្រាប់ដោះស្រាយនូវតម្រូវការខុសៗគ្នានៃទីផ្សារ និងបង្កើនភាពធន់ជាមួយការប្រែប្រួលអាកាសធាតុ។ ការងារនេះភាគច្រើនត្រូវអនុវត្តដោយស្ថាប័នសាធារណៈ ហើយក្នុងករណីចាំបាច់អាចសហការក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវកសិកម្មអន្តរជាតិ ឬតាមរយៈការលើកទឹកចិត្តដល់សហគ្រាសឯកជន និងគ្រឹះស្ថានវិជ្ជាជីវៈនានានៅក្នុងការអភិវឌ្ឍ និងការជ្រើសរើសពូជ ដើម្បីផ្ដល់លទ្ធភាពទូលំទូលាយដល់កសិករ និងអ្នកដាំដុះផ្សេងទៀតឱ្យមានជម្រើសច្រើនក្នុងការទទួលយកប្រភេទពូជសមស្របយកទៅដាំដុះ។ ការបង្កើតឱ្យមានច្បាប់ពាក់ព័ន្ធសិទ្ធិការពារប្រភេទពូជថ្មី គឺជាការលើកទឹកចិត្តមួយ ដល់ការវិនិយោគឯកជន ដូចបានកំណត់នៅផ្នែកក្រោយ នៃគោលនយោបាយនេះ។

២៣. វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា គឺជាអង្គភាពស្រាវជ្រាវកសិកម្មចម្បង ដែលអនុវត្តនូវកម្មវិធីបសិដ្ឋកម្មប្រភេទពូជស្រូវ និងប្រភេទពូជដំណាំដទៃទៀត។ ដៃគូអភិវឌ្ឍន៍នានា អាចចូលរួមក្នុងកម្មវិធីនេះ តាមរយៈការផ្តល់មូលនិធិសម្រាប់ពេលកំណត់ណាមួយ ក្រោមការត្រួតពិនិត្យជាទៀងទាត់របស់អង្គភាពសវនកម្មឯករាជ្យទៅលើវឌ្ឍនភាពនៃគម្រោង។ ការអភិវឌ្ឍប្រភេទពូជដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងស្របតាមតម្រូវការទីផ្សារ នឹងត្រូវទទួលបានការយកចិត្តទុកដាក់បន្ថែមទៀត។

២៤. ក្រុមហ៊ុនឬភ្នាក់ងារតាមមូលដ្ឋាន ត្រូវបានលើកទឹកចិត្តឱ្យរៀបចំធ្វើពិសោធន៍ប្រភេទពូជថ្មីនៅតាមតំបន់ផលិតកម្មសំខាន់ៗ ឬនៅស្ថានីយស្រាវជ្រាវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ ការនាំចូលប្រភេទពូជ សម្រាប់ធ្វើពិសោធន៍ ត្រូវផ្តល់ព័ត៌មានមកអង្គភាពគ្រប់គ្រងពូជដំណាំ ដើម្បីឱ្យមន្ត្រីបច្ចេកទេសធ្វើការត្រួតពិនិត្យនៅពេលដាំដុះតាមរដូវកាលតាមការចាំបាច់។ ការនាំចូលពូជដំណាំសម្រាប់ការពិសោធមុនការចុះបញ្ជី ត្រូវមានការសម្របសម្រួលដើម្បីទទួលបាននូវបរិមាណពូជដំណាំតាមការកំណត់សម្រាប់ដំណាំនីមួយៗ។

២៥. កម្ពុជាត្រូវធ្វើការអភិរក្សនូវប្រភពធនធានពន្ធុរបស់ខ្លួនជាចាំបាច់ ជាពិសេសប្រភេទពូជស្រូវប្រពៃណី ដើម្បីអាចបន្សាំទៅនឹងបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ប្រភពធនធានពន្ធុដ៏មានតម្លៃទាំងនេះ ត្រូវប្រើប្រាស់ក្នុងការអភិវឌ្ឍប្រភេទពូជថ្មីៗដែលអាចរក្សាបាននូវអត្តសញ្ញាណពូជដំណាំរបស់ជាតិ ហើយទន្ទឹមនឹងនោះក៏អាចបន្សាំបានយ៉ាងល្អទៅនឹងលក្ខខណ្ឌមូលដ្ឋានផងដែរ។ ការជ្រើសរើសប្រភេទពូជដំណាំប្រពៃណី ដោយផ្តោតលើចរិតលក្ខណៈពិសេសរបស់ពូជ នឹងផ្តល់ឱកាសក្នុងការបង្កើតផលិតផលមានទីផ្សារពិសេស ដែលអាចទាក់ទាញបានតម្លៃខ្ពស់សម្រាប់សហគមន៍ចូលរួមនៅក្នុងផលិតកម្ម។

២៦. ធនាគារពន្ធុដែលបានបង្កើតឡើងរួចហើយនៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ត្រូវទទួលការគាំទ្រពេញលេញ និងត្រូវរក្សានូវកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នជាតិ-អន្តរជាតិនានា ដើម្បីជំរុញកិច្ចការអភិរក្សនេះឱ្យមានដំណើរការទៅមុខ ព្រមទាំងត្រូវចងក្រងជាឯកសារអំពីប្រភេទពូជប្រពៃណី។ ការផ្លាស់ប្តូរពូជដំណាំនានាជាមួយបណ្តាអ្នកសហការ ត្រូវអនុវត្តតាមស្តង់ដារនៃកិច្ចសន្យាផ្ទេរសរីរាង្គដាំដុះ (Standard Material Transfer Agreement-SMTA)។ ក្រុមហ៊ុន អង្គការសង្គមស៊ីវិល និងភាគីដទៃទៀត ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តការអភិរក្សធនធានពន្ធុនៅនឹងកន្លែង និងក្នុងធនាគារពន្ធុ ចំពោះរាល់ពពួកដំណាំដែលមានចំណុចពិសេស សម្រាប់ជាប្រយោជន៍ណាមួយ។

### ៣.៣. ការពិសោធ និងការចុះបញ្ជីប្រភេទពូជដំណាំ

២៧. គណៈកម្មាធិការជាតិបញ្ចេញប្រភេទពូជដំណាំ (National Varietal Release Committee) ត្រូវបានបង្កើតឡើង ដើម្បីពិនិត្យលើដំណើរការវាយតម្លៃ និងការធ្វើសេចក្តីសម្រេចចិត្តក្នុងការបញ្ចេញ

ប្រភេទពូជថ្មីនៃដំណាំ។ ដំណើរការនៃការពិសោធ និងវាយតម្លៃ ចាំបាច់ត្រូវរៀបចំឱ្យមានឯកសណ្ឋានភាព និងអនុម័តដោយគណៈកម្មាធិការនេះ ហើយត្រូវបោះពុម្ពដោយអគ្គនាយកដ្ឋានកសិកម្ម ជាសេចក្តីណែនាំបច្ចេកទេសសម្រាប់ប្រភេទដំណាំផ្សេងៗគ្នា។ សមាជិកភាពរបស់គណៈកម្មាធិការនេះ នឹងត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធនានា។

**២៨.** អគ្គនាយកដ្ឋានកសិកម្ម ត្រូវរៀបចំបង្កើតបញ្ជីប្រភេទពូជដំណាំរបស់ជាតិ សម្រាប់ដំណាំចម្បងជាអាទិភាពមួយចំនួន ដែលជាប់កាតព្វកិច្ចក្នុងការចុះបញ្ជី។ បញ្ជីប្រភេទពូជដំណាំរបស់ជាតិត្រូវមានការបរិយាយសង្ខេបស្តីពីពូជនីមួយៗ និងសេចក្តីលម្អិតអំពីភាពបន្សាំ ការលូតលាស់ និងម្ចាស់កម្មសិទ្ធិ ឬប្រភពដើមនៃប្រភេទពូជនីមួយៗ។ បញ្ជីនេះជាប្រភពព័ត៌មានប្រភេទពូជដំណាំ ដែលត្រូវរាប់បញ្ចូលរាល់ប្រភេទពូជទាំងអស់ដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន និងសម្រាប់ប្រភេទពូជដែលមានប្រភពផ្គត់ផ្គង់ពូជដំណាំច្បាស់លាស់។ ប្រភេទពូជដែលមាននៅក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ អាចចាត់ទុកថាជាប្រភេទពូជដំណាំដែលមានអាទិភាពសម្រាប់ផលិតកម្ម ការធ្វើពាណិជ្ជកម្ម និងសម្រាប់ផលិតកម្មពូជដំណាំវិញ្ញាបនបត្រ។

**២៩.** បញ្ជីប្រភេទពូជដំណាំរបស់ជាតិត្រូវដាក់បញ្ចូលចំពោះប្រភេទពូជទាំងឡាយណាដែលទទួលបានពីប្រភពនៃកម្មវិធីបង្កាត់ និងជ្រើសរើសពូជច្បាស់លាស់ ដែលមានការពិពណ៌នាអំពីចរិកលក្ខណៈច្បាស់លាស់ ហើយបានដាក់ឈ្មោះត្រឹមត្រូវ។

**៣០.** បញ្ជីប្រភេទពូជដំណាំរបស់ជាតិត្រូវពិនិត្យឡើងវិញនៅក្នុងចន្លោះពេលមួយទៀងទាត់ ដោយគណៈកម្មាធិការជាតិបញ្ចេញប្រភេទពូជដំណាំ ដើម្បីដាក់បន្ថែមនូវប្រភេទពូជដែលបានបញ្ចេញឱ្យប្រើប្រាស់ ឬប្រភេទពូជណែនាំថ្មីដែលមានសក្តានុពលខ្ពស់ និងត្រូវលុបចេញនូវប្រភេទពូជទាំងឡាយណាដែលឈប់មានការប្រើប្រាស់ ឬមិនមានផលិតកម្មពូជដំណាំទៀត។

## ៣.៤ ការការពារប្រភេទពូជថ្មីនៃដំណាំ

**៣១.** ការការពារប្រភេទពូជថ្មីនៃដំណាំនៅក្នុងទម្រង់ជាកម្មសិទ្ធិបញ្ញា គឺជាកត្តាជំរុញដ៏សំខាន់ដល់ការវិនិយោគរបស់វិស័យឯកជន នៅក្នុងកម្មវិធីបង្កាត់ និងជ្រើសរើសពូជ ក៏ដូចជាក្នុងការនាំចូលពីបរទេសនូវប្រភេទពូជដែលមានការការពារត្រឹមត្រូវសម្រាប់ផលិតកម្ម និងទីផ្សារ។ ដើម្បីបំពេញតាមការតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក ការការពារប្រភេទពូជថ្មីនៃដំណាំ ត្រូវអនុវត្តទៅតាមខ្លឹមសារដែលបានកំណត់នៅក្នុងជំពូកទី២នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។ រុក្ខជម្រើសវិទូដែលមានបំណងការពារប្រភេទពូជថ្មីនៃដំណាំ ត្រូវដាក់ឯកសារ និងពាក្យស្នើសុំទៅកាន់ស្ថាប័នមានសមត្ថកិច្ច។

**៣២.** យោងតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ការងារបច្ចេកទេសសម្រាប់វាយតម្លៃប្រភេទពូជថ្មី ត្រូវអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយមន្ត្រី

សមត្ថកិច្ចជំនាញ ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញស្តីពីដំណើរការនៃការធ្វើតេស្តលើភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាព (DUS test) ដែលជាលក្ខណៈវិនិច្ឆ័យគន្លឹះ ក្នុងការការពារប្រភេទពូជថ្មីនៃដំណាំ។ មុននឹងឈានដល់ការណែនាំពេញលេញស្តីពីវិធានការការពារប្រភេទពូជថ្មីនៃដំណាំ អគ្គនាយកដ្ឋានកសិកម្ម ត្រូវរៀបចំបទដ្ឋានបច្ចេកទេសសម្រាប់ជាការណែនាំនៅក្នុងការអនុវត្តធ្វើតេស្ត ដែលត្រូវចាប់ផ្តើមពីពូជស្រូវ និងពោត និងដំណាំដទៃទៀតជាចាំបាច់។ ការពិព័ណនាអំពីប្រភេទពូជថ្មីដែលដាក់ស្នើសុំការពារ ត្រូវមានការផ្លាស់ប្តូរព័ត៌មានជាមួយបណ្តាប្រទេសក្នុងតំបន់ ដើម្បីធ្វើឱ្យនីតិវិធីនៃការធ្វើតេស្តកាន់តែមានប្រសិទ្ធភាព។ កិច្ចសហការនេះ នឹងត្រូវមានការសម្របសម្រួលនៅពេលកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ (International Union for the Protection of New Plant Varieties-UPOV)។

### ៣.៥ ពូជបម្លែងពន្ធុ (GMO)

**៣៣.** ការកែច្នៃពន្ធុរបស់ដំណាំដើម្បីអភិវឌ្ឍជាប្រភេទពូជបម្លែងពន្ធុ មានតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មនាពេលអនាគត ដើម្បីកែលម្អការលូតលាស់របស់ដំណាំនៅទីវាល បង្កើនភាពធន់ទ្រាំនឹងសមាសភាពចង្រៃ និងលើកកម្ពស់គុណភាពរបស់ផលិតផលដំណាំដែលទទួលបាន។ ព្រះរាជាណាចក្រកម្ពុជា បើកទូលាយក្នុងការធ្វើពិសោធ និងប្រើប្រាស់បច្ចេកទេសនេះ ក្នុងករណីដែលពិនិត្យឃើញថា គ្មានផលប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីត្រួតពិនិត្យការប្រើប្រាស់ និងការនាំចេញផលិតផលដែលដាំដុះដោយប្រើពូជបម្លែងពន្ធុស្របតាមការតម្រូវរបស់ភាគីពាណិជ្ជកម្ម។

**៣៤.** ការពិសោធពូជបម្លែងពន្ធុ ត្រូវអនុវត្តតាមពិធីសារជីវសុវត្ថិភាព បន្ថែមទៅលើដំណើរការអនុវត្តបទដ្ឋានបច្ចេកទេសក្សេត្រសាស្ត្ររបស់ប្រភេទពូជដំណាំធម្មតា។ ក្រុមប្រឹក្សាជាតិពូជដំណាំត្រូវតាមដានការងារនេះ ហើយអគ្គនាយកដ្ឋានកសិកម្ម ត្រូវរៀបចំលិខិតបទដ្ឋានចាំបាច់នានា។ ដើម្បីកាត់បន្ថយបាតុភាពនៃការធ្វើពាណិជ្ជកម្មឆ្លងដែនមិនផ្លូវការឬល្មើសច្បាប់ ព្រះរាជាណាចក្រកម្ពុជានឹងសហការជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ក្នុងក្របខណ្ឌនៃគោលនយោបាយ និងនីតិវិធីទាក់ទងនឹងពូជបម្លែងពន្ធុនេះ។

### ៣.៦ ផលិតកម្ម និងការផ្គត់ផ្គង់ពូជដំណាំ

**៣៥.** ផលិតកម្មពូជដំណាំនៅកម្ពុជា ត្រូវបានជំរុញលើកទឹកចិត្ត ជាពិសេសដំណាំស្រូវ និងដំណាំចម្ការសំខាន់ៗមួយចំនួន ដូចជាពោត និងពពួកសណ្តែក។ គ្រប់ប្រភេទពូជដំណាំត្រូវចុះឈ្មោះក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ ហើយត្រូវមានវិញ្ញាបនបត្របញ្ជាក់គុណភាពផងដែរ។ គ្រាប់ពូជពោតអ៊ីប្រ៊ីត និងគ្រាប់ពូជបន្លែមួយចំនួន អាចអនុញ្ញាតឱ្យនាំចូលតាមរយៈពាណិជ្ជកម្មក្នុងតំបន់ ឬអន្តរជាតិ រហូតដល់ផលិតកម្មពូជដំណាំទាំងនេះនៅក្នុងស្រុកមានលទ្ធភាពអាចផ្គត់ផ្គង់បានគ្រប់គ្រាន់។

៣៦. រុក្ខជម្រើសវិទូ ឬអង្គភាពបង្កាត់ និងជ្រើសរើសប្រភេទពូជ មានតួនាទីទទួលខុសត្រូវក្នុងការថែរក្សាស្តុកពូជដំណាំជម្រើសវិទូនៃប្រភេទពូជរបស់ខ្លួននៅក្នុងស្ថានភាពដើម ហើយត្រូវផលិតពូជដំណាំនៅជំនាន់ដំបូងៗរហូតដល់ពូជដំណាំគ្រឹះ ដរាបណានៅមានសេចក្តីត្រូវការពូជដំណាំនេះនៅលើទីផ្សារ។ ឈ្មោះនៃរុក្ខជម្រើសវិទូ ឬអ្នកមានសិទ្ធិថែរក្សាពូជដំណាំ ត្រូវបានកត់ត្រានៅក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ។ សម្រាប់ប្រភេទពូជដែលបានអភិវឌ្ឍនៅក្រៅប្រទេស ក្រុមហ៊ុនក្នុងស្រុក ឬគ្រឹះស្ថានដទៃទៀត អាចស្នើសុំចុះឈ្មោះជាអ្នកថែរក្សាប្រភេទពូជនេះបាន ក្នុងករណីមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ក្នុងការអនុវត្តការងារនេះ ដោយត្រូវជូនដំណឹងទៅម្ចាស់ដើម។ ផលិតកម្មគ្រាប់ពូជជម្រើសវិទូមិនស្ថិតក្នុងកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬការផ្តល់វិញ្ញាបនបត្រឡើយ ពីព្រោះការងារនេះស្ថិតនៅក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់ម្ចាស់ពូជដំណាំ។

៣៧. ផលិតកម្មពូជដំណាំគ្រឹះ ត្រូវបានធានាមិនឱ្យមានឧបសគ្គផ្នែកហិរញ្ញវត្ថុឬកត្តាដទៃទៀតឡើយ ពីព្រោះជាការចាប់ផ្តើមនៃប្រព័ន្ធផលិតកម្មពូជដំណាំសម្រាប់ធ្វើការចែកចាយ។ ក្រុមហ៊ុន និងគ្រឹះស្ថានផលិតពូជដំណាំគ្រឹះ ត្រូវផ្តល់ព័ត៌មានស្តីពីបរិមាណផលិតកម្ម និងការប្រើប្រាស់ប្រចាំឆ្នាំរបស់ខ្លួន ទៅអង្គភាពគ្រប់គ្រងពូជដំណាំ។ ស្រែផលិតកម្មពូជដំណាំគ្រឹះ ត្រូវស្ថិតក្នុងកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព តាមរយៈការរៀបចំរួមគ្នារវាងរុក្ខជម្រើសវិទូឬអ្នកទទួលសិទ្ធិថែរក្សាប្រភេទពូជ និងសមត្ថកិច្ចផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ។

៣៨. ការនាំពង្រីកពូជដំណាំគ្រឹះបន្តទៅពូជដំណាំពីរជំនាន់ទៀត គឺពូជដំណាំចុះបញ្ជី និងពូជដំណាំវិញ្ញាបនបត្រ ត្រូវមានការត្រួតពិនិត្យដោយប្រព័ន្ធបញ្ជាក់គុណភាពពូជដំណាំ ដើម្បីអាចរក្សាបានភាពសុទ្ធ និងអាចបង្កើនអត្ថប្រយោជន៍ជាអតិបរមាដល់កសិករ និងអ្នកដាំដុះផ្សេងទៀត។ ពូជដំណាំគ្រឹះត្រូវមានបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ឱ្យក្រុមហ៊ុន និងគ្រឹះស្ថាននានាសម្រាប់បន្តធ្វើផលិតកម្មពង្រីកពូជដំណាំ និងលក់ចែកចាយប្រកបដោយភាពទទួលខុសត្រូវ។ ស្តង់ដារពូជដំណាំ និងដំណើរការផលិតសម្រាប់គ្រប់ចំណាត់ថ្នាក់នៃពូជដំណាំ ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣៩. ផលិតកម្ម និងទីផ្សារពូជដំណាំគ្រឹះ និងពូជដំណាំចុះបញ្ជី អាចត្រូវការជំនួយគាំទ្រដើម្បីពង្រឹងប្រព័ន្ធផ្គត់ផ្គង់ពូជដំណាំចំណាត់ថ្នាក់នេះ និងធានាដល់ការផ្គត់ផ្គង់ពូជដំណាំវិញ្ញាបនបត្រឱ្យបានគ្រប់គ្រាន់ដល់កសិករ និងអ្នកដាំដុះផ្សេងទៀត។ ផលិតកម្ម និងការផ្គត់ផ្គង់ពូជដំណាំវិញ្ញាបនបត្រ ត្រូវធ្វើឡើងតែជាលក្ខណៈពាណិជ្ជកម្ម។ ការចែកចាយ ឬការផ្តល់អំណោយពូជដំណាំ អាចប្រព្រឹត្តទៅបានសម្រាប់តែកសិករក្រីក្រ និងក្នុងករណីជួបប្រទះគ្រោះធម្មជាតិ។

៤០. ការធ្វើពិពិធកម្មប្រព័ន្ធផ្គត់ផ្គង់ពូជដំណាំ គឺជាអាទិភាពខ្ពស់មួយដើម្បីបង្កើតទីផ្សារដែលមានការប្រកួតប្រជែង ព្រមទាំងបង្កើនឱកាសដល់កសិករ និងអ្នកដាំដុះផ្សេងទៀត ក្នុងការជ្រើសរើសប្រភេទពូជមកដាំដុះ និងអ្នកផ្គត់ផ្គង់ពូជដំណាំនៅលើទីផ្សារ។ ផលិតករ និងអាជីវករថ្មី ត្រូវបានទទួលស្គាល់នៅ

ក្នុងទីផ្សារពូជដំណាំ ហើយឧបសគ្គនានាដែលអាចកើតមានចំពោះការចូលរួមនេះ ត្រូវដោះស្រាយឱ្យមានប្រសិទ្ធភាព។

៤១. ការប្រើប្រាស់ផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ផលិតពូជដំណាំនឹងត្រូវលើកទឹកចិត្តឱ្យបានខ្លាំងក្លា ព្រោះជាយន្តការមួយដែលជួយជំរុញដល់ការផលិតពូជដំណាំដែលមានគុណភាពល្អ និងផ្តល់ផលប្រយោជន៍ជាច្រើនដល់កសិករ និងអ្នកដាំដុះផ្សេងទៀត។ ការផលិតពូជដំណាំតាមបែបកសិកម្មតាមកិច្ចសន្យា អាចផ្តល់ជាមធ្យោបាយផ្សព្វផ្សាយដ៏មានតម្លៃ សម្រាប់បង្ហាញបច្ចេកទេសកសិកម្មល្អនៅក្នុងសហគមន៍។ ជាចាំបាច់ត្រូវបង្កើតវគ្គបណ្តុះបណ្តាលអំពីដំណើរការនៃកិច្ចសន្យា ដើម្បីធានាឱ្យភាគីទាំងអស់គោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា និងបង្កើនទំនាក់ទំនងល្អនៅក្នុងខ្សែរសង្វាក់ផលិតកម្មពូជដំណាំ។

៤២. អ្នកកែច្នៃ និងអ្នកនាំចេញផលិតផលកសិកម្ម ត្រូវបានលើកទឹកចិត្ត និងគាំទ្រឱ្យចូលរួមនៅក្នុងខ្សែរសង្វាក់ផ្គត់ផ្គង់ពូជដំណាំ ដើម្បីជំរុញផលិតកម្មពូជដំណាំនៃប្រភេទពូជដែលមានតម្រូវការច្រើនជាងគេ និងកាត់បន្ថយអត្រានៃផលិតផលអន់គុណភាពនៅលើទីផ្សារ។ ទំនាក់ទំនងជិតស្និទ្ធនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ពូជដំណាំរហូតដល់ទីផ្សារ និងការកែច្នៃ គឺជាគោលការណ៍គ្រឹះនៃគោលនយោបាយនេះដែលជាមធ្យោបាយលើកកម្ពស់គុណភាពផលិតផលកសិកម្មសម្រាប់ការនាំចេញ។

៤៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើកទឹកចិត្តដល់គំនិតផ្តួចផ្តើមរបស់សហគមន៍ផលិតពូជដំណាំ អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការមូលដ្ឋាននានា ដែលមានបំណងផលិតពូជដំណាំសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋាន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ការគាំទ្រនិងទទួលស្គាល់ផលិតករពូជដំណាំនៅមូលដ្ឋានទាំងឡាយណាដែលបានគោរពតាមស្តង់ដារជាក់លាក់ក្នុងគោលបំណងបង្កើនការផ្គត់ផ្គង់ពូជដំណាំមានគុណភាពល្អ និងបង្កើតឱកាសទីផ្សារល្អប្រសើរដល់ផលិតផលរបស់សហគមន៍។

៤៤. បទពិសោធន៍លើភាពជោគជ័យរបស់ក្រុម និងសហគមន៍ផលិតពូជដំណាំនៅតាមមូលដ្ឋានត្រូវចងក្រងទុកជាឯកសារដោយអង្គភាពគ្រប់គ្រងពូជដំណាំ ដើម្បីផ្តល់ការណែនាំដល់ក្រុមថ្មីៗ និងសម្រាប់ពង្រឹងក្រុមដែលបានបង្កើតរួច។ ក្រមប្រតិបត្តិជាមូលដ្ឋានសម្រាប់ក្រុម និងសហគមន៍ផលិតពូជដំណាំ ព្រមទាំងសមាជិក នឹងត្រូវរៀបចំឡើងដោយអង្គភាពគ្រប់គ្រងពូជដំណាំ ផ្អែកលើការអនុវត្តល្អៗនាពេលកន្លងមក។

៤៥. អគ្គនាយកដ្ឋានកសិកម្មត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់ផលិតកម្មពូជដំណាំ នូវប្រភេទដំណាំសំខាន់ៗ សំដៅធានាដល់ការផ្គត់ផ្គង់ពូជដំណាំ ដែលមានគុណភាពខ្ពស់បានគ្រប់គ្រាន់។ ក្រុមប្រឹក្សាជាតិពូជដំណាំ ត្រូវតាមដានការអនុវត្តផែនការសកម្មភាពទាំងនេះ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍទីផ្សារពូជដំណាំទាំងក្នុងស្រុក និងអន្តរជាតិ។

៤៦. ផ្អែកតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត មានតួនាទីសំខាន់ក្នុងការសម្របសម្រួលផលិតកម្មនិងការផ្គត់ផ្គង់ពូជដំណាំក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចការនេះត្រូវអនុវត្តដោយផ្សារភ្ជាប់ជាមួយសកម្មភាពផ្សព្វផ្សាយដើម្បីធានាថាការផ្គត់ផ្គត់ពូជដំណាំលែងជាឧបសគ្គសម្រាប់កសិករ និងអ្នកដាំដុះផ្សេងទៀត នៅពេលដែលអ្នកដាំដុះមានការយល់ដឹងអំពីពូជបសិដ្ឋកម្ម និងពូជដំណាំដែលមានគុណភាពល្អ។

៤៧. ទោះបីជាគោលនយោបាយនេះ មានគោលបំណងជំរុញការអភិវឌ្ឍឧស្សាហកម្មពូជដំណាំក្នុងលក្ខណៈពាណិជ្ជកម្មក្តី ក៏តម្រូវការពូជដំណាំក្នុងបរិមាណដ៏ច្រើន នៅតែបន្តផ្គត់ផ្គង់ដោយប្រភពក្រៅឧស្សាហកម្មដែរ នៅក្នុងរយៈពេលខ្លីខាងមុខនេះ។ ដើម្បីបង្កើនគុណភាពពូជដំណាំទាំងនោះ អគ្គនាយកដ្ឋានកសិកម្មត្រូវសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ក្នុងការជំរុញឱ្យមានការកែលម្អការគ្រប់គ្រងពូជដំណាំរបស់កសិករ និងអ្នកដាំដុះផ្សេងទៀតក្នុងការថែរក្សាពូជដំណាំដែលបានរក្សាទុកដោយខ្លួនឯងឬបានដោះដូរក្នុងសហគមន៍។

៤៨. ការធ្វើពិពិធកម្មប្រព័ន្ធដាំដុះដំណាំ គឺជាអាទិភាពមួយក្នុងការបង្កើនប្រាក់ចំណូល អាហារូបត្ថម្ភ និងសន្តិសុខស្បៀង ជាពិសេសតាមរយៈការណែនាំដំណាំអម្បូរសណ្តែកសម្រាប់កសិករ និងអ្នកដាំដុះផ្សេងទៀត។ ទោះបីជាយ៉ាងនេះក្តី ក៏ប្រភេទដំណាំទាំងនោះមិនសូវទទួលបានការចាប់អារម្មណ៍ពីក្រុមហ៊ុនពាណិជ្ជកម្មពូជដំណាំដែរ ដោយសារផលិតកម្មពូជដំណាំនៃប្រភេទដំណាំទាំងនោះទទួលបានប្រាក់ចំណូលតិច។ ក្នុងករណីការផ្គត់ផ្គង់ពូជដំណាំមានឧបសគ្គនៅក្នុងការងារធ្វើពិពិធកម្មកសិកម្ម ប្រព័ន្ធពូជដំណាំនៅមូលដ្ឋានត្រូវបានប្រើប្រាស់ដើម្បីធានាការផ្គត់ផ្គង់ពូជដំណាំទាំងនោះក្នុងកម្រិតអប្បបរមាទៅដល់កសិករ និងអ្នកដាំដុះផ្សេងទៀត។

៤៩. ដើម្បីផលប្រយោជន៍របស់កសិករ និងអ្នកដាំដុះផ្សេងទៀត ក្រុមហ៊ុនដែលនាំចូលគ្រាប់ពូជអ៊ីប្រ៊ីតរួមទាំងគ្រាប់ពូជពោត ត្រូវធ្វើការពិសោធសាកល្បង និងចុះបញ្ជីដើម្បីបញ្ជាក់ថា ពូជដំណាំដែលមានគុណភាពល្អ ត្រូវបានចែកចាយ និងរកបានសម្រាប់ធ្វើការដាំដុះ។

៥០. ការបង្កើនផលិតកម្មបន្លែ គឺជាអាទិភាពចម្បងមួយរបស់កម្ពុជា ក្នុងការបង្កើនអាហារូបត្ថម្ភគ្រួសារ ដើម្បីជំនួសការនាំចូល និងបង្កើនប្រាក់ចំណូលកសិករ និងអ្នកដាំដុះផ្សេងទៀត។ ដូចគ្នានឹងដំណាំពោតដែរ ទីផ្សារគ្រាប់ពូជបន្លែមានការប្រកួតប្រជែងខ្លាំង ហើយភាគច្រើនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិស័យឯកជន។ ដោយសារមានពូជបន្លែល្អៗជាច្រើននៅក្នុងពាណិជ្ជកម្មអន្តរជាតិ និងការទទួលអត្ថប្រយោជន៍ពីការប្រើប្រាស់គ្រាប់ពូជមានគុណភាពខ្ពស់ ទីផ្សារនេះនឹងបន្តផ្គត់ផ្គង់ដោយការនាំចូលរហូតដល់ផលិតកម្មគ្រាប់ពូជបន្លែនៅក្នុងស្រុកមានសមត្ថភាពផ្គង់ផ្គង់បានគ្រប់គ្រាន់។ ដូច្នេះភាពជាដៃគូរវាងក្រុមហ៊ុន និងគម្រោងអភិវឌ្ឍន៍គ្រាប់ពូជបន្លែនានា ត្រូវបានលើកទឹកចិត្តដើម្បីបង្កើនការទទួលយកបច្ចេកទេសផលិតកម្មបន្លែទំនើបដោយកសិកម្មខ្នាតតូច។





៥១. ព័ត៌មានស្តីពីការលូតលាស់ និងភាពបន្សាំរបស់ពូជបន្លែ គឺជាព័ត៌មានសំខាន់ជាគន្លឹះសម្រាប់កសិករ និងអ្នកដាំដុះផ្សេងទៀត។ ក្រុមហ៊ុននាំចូលគ្រាប់ពូជបន្លែ ត្រូវផ្តល់ព័ត៌មានឱ្យបានលម្អិត និងច្បាស់លាស់ ដោយរៀបចំបរិយាយប័ណ្ណ ឬស្លាកព័ត៌មានអំពីប្រភេទពូជបន្លែរបស់ខ្លួន។ បរិយាយប័ណ្ណ ឬស្លាកព័ត៌មាននេះ ត្រូវថតចម្លងមួយច្បាប់ផ្ញើមកអង្គភាពគ្រប់គ្រងពូជដំណាំជារៀងរាល់ឆ្នាំ ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានអេឡិចត្រូនិក សម្រាប់រក្សាទុកជាមូលដ្ឋានទិន្នន័យព័ត៌មានគ្រាប់ពូជបន្លែ។

៥២. ចំពោះដំណាំពហុវដ្ត ក៏ត្រូវរៀបចំឱ្យមានប្រព័ន្ធវិញ្ញាបនបត្រ ដើម្បីបង្កើនគុណភាព និងសុខភាពនៃពូជដំណាំ ដែលជាដំណាក់កាលមួយដ៏សំខាន់នៅក្នុងការធ្វើបសិដ្ឋកម្មផលិតកម្មដំណាំប្រភេទនេះ។ អគ្គនាយកដ្ឋានកសិកម្មត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស ដែលជាជំនួយដល់អ្នកផលិតដែលមានបំណងចង់បង្កើនស្តង់ដារពូជដំណាំ និងសរីរាង្គដាំដុះនៃប្រភេទដំណាំទាំងនោះ។

### ៣.៧ ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ

៥៣. កង្វះការយល់ដឹងរបស់កសិករ និងអ្នកដាំដុះផ្សេងទៀតអំពីសារៈសំខាន់នៃប្រភេទពូជ និងគុណភាពពូជដំណាំ គឺជាឧបសគ្គចម្បងក្នុងការអភិវឌ្ឍឧស្សាហកម្មពូជដំណាំសម្រាប់ទីផ្សារ។ ក្នុងហេតុផលនេះ អគ្គនាយកដ្ឋានកសិកម្ម និងស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវជំរុញយុទ្ធនាការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសារៈសំខាន់នៃប្រភេទពូជ និងគុណភាពពូជដំណាំ ដោយចាត់ទុកការងារនេះជាអាទិភាពខ្ពស់។ នៅក្នុងការបង្ហាញ និងការរៀបចំទិវាស្រែ ត្រូវបញ្ចូលនូវព័ត៌មានអំពីប្រភេទពូជ គុណភាពពូជដំណាំ និងប្រភពពូជដំណាំសម្រាប់រដូវដាំដុះបន្ទាប់។ វិធីសាស្រ្តនេះក៏ត្រូវអនុវត្តដូចគ្នានៅក្នុងការជំរុញផលិតកម្មពូជដំណាំតាមមូលដ្ឋាន ដោយសហគមន៍ផលិតពូជដំណាំ និងក្រុមកសិករដទៃទៀត។

៥៤. អង្គភាពគ្រប់គ្រងពូជដំណាំ ត្រូវសហការ និងសម្របសម្រួលជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងគម្រោងអភិវឌ្ឍន៍នានា ដើម្បីរៀបចំបោះពុម្ពឯកសារបច្ចេកទេស និងសម្ភារផ្សព្វផ្សាយផ្សេងទៀត សម្រាប់គាំទ្រដល់សកម្មភាពផលិតពូជដំណាំ និងការប្រើប្រាស់ពូជដំណាំដែលមានគុណភាពល្អឱ្យបានទូលំទូលាយដោយកសិករ និងអ្នកដាំដុះផ្សេងទៀតនៅក្នុងមូលដ្ឋាន។

៥៥. អគ្គនាយកដ្ឋានកសិកម្ម និងស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រសកម្មភាពបណ្តុះបណ្តាល និងការងារអប់រំកសិករ និងអ្នកដាំដុះផ្សេងទៀត អំពីការប្រើប្រាស់ពូជដំណាំដែលមានគុណភាពខ្ពស់ ជាពិសេសពូជដំណាំទាំងឡាយណាដែលអ្នកដាំដុះរក្សាទុកពូជដំណាំដោយខ្លួនឯង តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត អង្គភាពឬគ្រឹះស្ថានផលិតពូជដំណាំ និងអង្គការមិនមែនរដ្ឋាភិបាល។

៥៦. អគ្គនាយកដ្ឋានកសិកម្ម ត្រូវសហការ និងសម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងការលើកទឹកចិត្ត និងគាំទ្រដាក់បញ្ចូលមុខវិជ្ជាពាក់ព័ន្ធនឹងប្រភេទពូជ និងផលិតកម្មពូជ

ដំណាំទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំ និងស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ចំណេះដឹងជាមូលដ្ឋានលើប្រធានបទនេះ ដល់ស្រទាប់យុវជន និងអ្នកឯកទេសកសិកម្មជំនាន់ក្រោយ។

## ៣.៨ ការនាំចូល និងនាំចេញពូជដំណាំ

**៥៧.** ចំពោះមុខ ត្រូវជំរុញឱ្យកសិករ និងអ្នកដាំដុះផ្សេងទៀត ទទួលបាននូវពូជដំណាំមានគុណភាពល្អនៃប្រភេទដំណាំដែលបានធ្វើបសិដ្ឋកម្ម ដើម្បីបង្កើនផលិតភាពកសិកម្ម និងអាចបង្កើតកាលានុវត្តភាព និងការប្រកួតប្រជែងទីផ្សារផងដែរ។ ដូចបានបញ្ជាក់ខាងលើ គ្រាប់ពូជពោតអ៊ីប្រ៊ីត និងគ្រាប់ពូជបន្លែភាគច្រើន ត្រូវបាននាំចូល ហើយស្ថានភាពនេះនឹងអាចអូសបន្លាយបន្តទៀតនៅក្នុងរយៈពេលខ្លីទៅមធ្យម។ អាស្រ័យហេតុនេះ ជាចាំបាច់ត្រូវមានការសម្របសម្រួលល្អលើដំណើរការបច្ចេកទេស និងនីតិវិធីរដ្ឋបាលនៃការនាំចូល ដើម្បីកាត់បន្ថយជាអតិបរមានូវសកម្មភាពក្រៅផ្លូវការទាំងឡាយ។

**៥៨.** ពូជដំណាំដែលនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញលក្ខខណ្ឌតម្រូវភូតគាមអនាម័យ និងស្តង់ដារគុណភាពពូជដំណាំ ព្រមទាំងដាក់ស្លាកព័ត៌មានជាភាសាខ្មែរឱ្យបានត្រឹមត្រូវ។ បទប្បញ្ញត្តិស្តីពីភូតគាមអនាម័យនៃពូជដំណាំ ត្រូវផ្អែកលើការវិភាគហានិភ័យសមាសភាពចង្រៃ។ កិច្ចសហការជាមួយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសជិតខាង អាចជួយសម្រួលដល់ការងារត្រួតពិនិត្យភូតគាមអនាម័យ ពីព្រោះការគំរាមកំហែងនៃសមាសភាពចង្រៃសំខាន់ៗ មានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងតំបន់។

**៥៩.** គ្រាប់ពូជបន្លែដែលនាំចូល ត្រូវលក់ចែកចាយក្នុងសំបកវេចខ្ចប់ដើមជាចាំបាច់ ដើម្បីរក្សាគុណភាពគ្រាប់ពូជ និងអត្តសញ្ញាណប្រភេទពូជនៅលើទីផ្សារ។ ដើម្បីជួយគាំទ្រ និងការពារផលប្រយោជន៍កសិករ និងអ្នកដាំដុះផ្សេងទៀត អគ្គនាយកដ្ឋានកសិកម្ម ត្រូវជំរុញឱ្យប្រតិបត្តិករនាំចូលធ្វើការបោះពុម្ពនូវបរិយាយប័ណ្ណ ឬស្លាកសញ្ញាព័ត៌មានអំពីពូជដំណាំនោះជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ ស្របតាមគោលការណ៍ណែនាំ ស្តីពីស្លាកសញ្ញាព័ត៌មានពូជដំណាំ។ ការវេចខ្ចប់ឡើងវិញនូវពូជដំណាំនាំចូល ត្រូវផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋានកសិកម្ម ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញលើភាពអនុលោម ដែលអាចប៉ះពាល់ដល់គុណភាពពូជដំណាំ។

**៦០.** បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់មានលទ្ធភាពនាំចេញពូជដំណាំឡើយ។ ប៉ុន្តែក្រុមហ៊ុនអន្តរជាតិមួយចំនួនដែលធ្វើសកម្មភាពផ្នែកពាណិជ្ជកម្មពូជបន្លែ និងផ្កា កំពុងមានការចាប់អារម្មណ៍ក្នុងការស្វែងរកទីតាំងថ្មីៗ ជាពិសេសនៅតំបន់ខ្ពង់រាប ដើម្បីធ្វើកិច្ចសន្យាផលិតកម្ម។ រាជរដ្ឋាភិបាលកម្ពុជា អាចបង្ហាញអំពីកាលានុវត្តភាពសម្រាប់ពាណិជ្ជកម្មពូជដំណាំនេះ និងជួយសម្របសម្រួលឱ្យក្រុមហ៊ុនបរទេសដែលមានបំណងធ្វើពិសោធន៍ការដាំដុះនៅកម្ពុជា។ ក្រុមហ៊ុនឯកជនក្នុងស្រុក អាចភ្ជាប់ទំនាក់ទំនងជាមួយក្រុមហ៊ុនបរទេស ដើម្បីអភិវឌ្ឍផលិតកម្ម និងពាណិជ្ជកម្មពូជដំណាំនៅកម្ពុជា។

## ៣.៩ បទដ្ឋានគតិយុត្តនៅក្នុងឧស្សាហកម្មពូជដំណាំ

**៦១.** គោលបំណងចម្បងនៃក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តនៅក្នុងការគ្រប់គ្រងពូជដំណាំ គឺដើម្បីលើកកម្ពស់ស្តង់ដារពូជដំណាំនៅលើទីផ្សារ ព្រមទាំងជួយការពារផលប្រយោជន៍របស់កសិករ និងអ្នកដាំដុះផ្សេងទៀតដែលជួបបញ្ហាក្លែងបន្លំគុណភាព។ រាល់ដំណើរការអនុវត្តច្បាប់ ត្រូវប្រើប្រាស់បទដ្ឋានគតិយុត្តដែលមានស្រាប់ដើម្បីបំពេញនីតិវិធីជាក់លាក់ និងត្រូវបញ្ចូលជាជំហានៗនូវបទដ្ឋានគតិយុត្តថ្មីតាមការអភិវឌ្ឍ និងវិវត្តនៃឧស្សាហកម្មពូជដំណាំ។ បទដ្ឋានគតិយុត្តអាទិភាពរួមមាន ស្តង់ដារគុណភាពពូជដំណាំ ការចុះបញ្ជីប្រភេទពូជដំណាំ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ដែលកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវជំរុញការអនុវត្តដោយអង្គភាពគ្រប់គ្រងពូជដំណាំ។

**៦២.** អង្គភាពគ្រប់គ្រងពូជដំណាំ ត្រូវត្រួតពិនិត្យ និងតាមដានគុណភាពពូជដំណាំ ដែលធ្វើចរាចរណ៍នៅលើទីផ្សារ ដោយត្រូវប្រមូលសំណាកពូជដំណាំនៅកន្លែងលក់ និងចាត់វិធានការជំរុញការអនុវត្តច្បាប់ ឬពិន័យអន្តរការណ៍ស្របតាមច្បាប់ជាធរមាន ក្នុងករណីត្រួតពិនិត្យឃើញថា ពូជដំណាំដែលដាក់តាំងលក់មានបញ្ហាគុណភាព។ ក្នុងករណីសង្ស័យថា ពូជដំណាំដែលដាក់តាំងលក់ក្លែងគុណភាព ភ្នាក់ងារពូជដំណាំនៃអង្គភាពគ្រប់គ្រងពូជដំណាំ ត្រូវស្រាវជ្រាវរកបទល្មើសជាក់ស្តែង ប្រមូលវត្ថុតាងនៃបទល្មើស និងចងក្រងសំណុំរឿងនៃបទល្មើស ដោយដាក់បន្ទុកចោទប្រកាន់ពីបទក្លែងគុណភាពពូជដំណាំ ឬពីបទក្លែងស្លាកសញ្ញាព័ត៌មានឬក្លែងសំបកវេចខ្ចប់ ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។ ភ្នាក់ងារពូជដំណាំមានសមត្ថកិច្ចនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវតាមដាន និងស្រាវជ្រាវនូវករណីក្លែងបន្លំដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវរាយការណ៍ជូនអង្គភាពគ្រប់គ្រងពូជដំណាំ ដើម្បីចុះធ្វើការស្រាវជ្រាវពេញលេញ និងចាត់វិធានការជំរុញការអនុវត្តច្បាប់តាមនីតិវិធី។

**៦៣.** ដើម្បីអនុវត្តប្រព័ន្ធផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ជាចាំបាច់ត្រូវបង្កើតមន្ទីរពិសោធន៍វិភាគគុណភាពពូជដំណាំ ដែលចំណុះក្រោមមន្ទីរពិសោធន៍ជាតិកសិកម្ម។ អគ្គនាយកដ្ឋានកសិកម្ម ត្រូវវិភាជន៍ធនធានសម្រាប់ដំណើរការមន្ទីរពិសោធន៍ពូជដំណាំ និងត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញដែលបម្រើការងារក្នុងមន្ទីរពិសោធន៍នេះ។ ក្រៅពីការគាំទ្រដល់ដំណើរការផ្តល់វិញ្ញាបនបត្រ មន្ទីរពិសោធន៍មានតួនាទីត្រួតពិនិត្យគុណភាពពូជដំណាំផ្សេងទៀត ដូចជាការធ្វើតេស្តលើគុណភាពពូជដំណាំនាំចូល និងការសិក្សាលើករណីពូជដំណាំខូចគុណភាពដែលចរាចរលើទីផ្សារជាដើម។

**៦៤.** អង្គភាពគ្រប់គ្រងពូជដំណាំ ត្រូវរៀបចំស្តង់ដារ និងពិធីសារបច្ចេកទេសដើម្បីផ្តល់លទ្ធភាពឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត អាចធ្វើតេស្តលើដំណុះពូជដំណាំ ដោយប្រើឧបករណ៍សាមញ្ញ និងការចំណាយតិចដែលអាចជួយសម្រួលដល់ការត្រួតពិនិត្យគុណភាពពូជដំណាំរបស់អ្នកផលិតនៅមូលដ្ឋាន។ ការងារនេះអាចជួយដោះស្រាយបញ្ហាបច្ចេកទេសដែលមាននៅក្នុងផលិតកម្មពូជដំណាំរបស់អ្នកផលិតនៅមូលដ្ឋានសាមី។





៦៥. ការសម្របសម្រួលឱ្យមានការប្រកួតប្រជែងទីផ្សារពូជដំណាំ នៅក្នុងបរិយាកាសពាណិជ្ជកម្មសមស្រប ដើរតួយ៉ាងសំខាន់ក្នុងការបង្កើនគុណភាពពូជដំណាំ ជាពិសេសចំពោះក្រុមដំណាំដែលមានតម្លៃខ្ពស់ ដូចជាពពួកបន្លែជាដើម។ ក្នុងបរិបទនេះ ចាំបាច់ត្រូវធ្វើឱ្យការនាំចូលពូជដំណាំប្រកបដោយតម្លាភាព និងភាពងាយស្រួល ដើម្បីកាត់បន្ថយពាណិជ្ជកម្មឆ្លងដែនមិនផ្លូវការ ឬល្មើសច្បាប់ ដែលអាចបង្កហានិភ័យខ្ពស់ ដូចជាការនាំចូលនូវពូជដំណាំអន់គុណភាព និងពូជដំណាំក្លែងបន្លំជាដើម។

## ៣.១០ ហិរញ្ញប្បទានក្នុងឧស្សាហកម្មពូជដំណាំ

៦៦. គោលដៅចម្បងមួយនៃគោលនយោបាយនេះ គឺការបង្កើតឱ្យមានការគ្រប់គ្រងពូជដំណាំមួយដែលធានានិរន្តរភាពហិរញ្ញវត្ថុ និងឆ្លើយតបតាមតម្រូវការទីផ្សារ។ ការវិនិយោគភាគច្រើន អាចមានប្រភពចេញមកពីវិស័យឯកជន នៅពេលដែលទទួលបានកាលានុវត្តភាពល្អក្នុងការធ្វើពាណិជ្ជកម្មពូជដំណាំ។ តួនាទីសំខាន់របស់ស្ថាប័នសាធារណៈនៅក្នុងគោលនយោបាយនេះ គឺបង្កើតឱ្យមានបរិយាកាសប្រកបដោយសុវត្ថិភាព និងអំណោយផលសម្រាប់ការវិនិយោគឯកជន និងការប្រើមូលនិធិសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្រាប់គាំទ្រគោលបំណងនេះ។ ដើម្បីធានានិរន្តរភាព វិស័យឯកជនត្រូវមានការទទួលខុសត្រូវលើផលិតកម្ម និងទីផ្សារពូជដំណាំ ប៉ុន្តែចាំបាច់ត្រូវសហការជាមួយសេវាផ្សព្វផ្សាយសាធារណៈ ក្នុងការពង្រឹងគុណភាព និងការអភិវឌ្ឍទីផ្សារ។

៦៧. ថវិកាដែលទទួលបានពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ត្រូវប្រើប្រាស់ជាចម្បងសម្រាប់ការងារជាយុទ្ធសាស្ត្រមួយចំនួនដូចជា ការបង្កាត់ពូជ ការជ្រើសរើសពូជ ការរក្សានូវភាពដើមរបស់ពូជ និងការផលិតគ្រាប់ពូជគ្រឹះនៃដំណាំសំខាន់ៗជាអាទិភាពរបស់ជាតិ ប៉ុន្តែជាប្រភេទពូជដំណាំដែលគ្មាន ឬមានការយកចិត្តទុកដាក់តិចតួចក្នុងការវិនិយោគរបស់វិស័យឯកជន។ ថវិកាដែលទទួលបានពីរាជរដ្ឋាភិបាល ក៏ត្រូវប្រើប្រាស់សម្រាប់សេវាកម្មសំខាន់ៗផងដែរដូចជា ការពិសោធ ការត្រួតពិនិត្យនៅលើទីវាល ការធ្វើតេស្ត ការធ្វើស្រែបង្ហាញ និងការបណ្តុះបណ្តាលដល់អ្នកផលិតពូជដំណាំ។

៦៨. ដើម្បីជំរុញការប្រើប្រាស់ពូជដំណាំដែលមានគុណភាពខ្ពស់ ការត្រួតពិនិត្យគុណភាព ត្រូវអនុវត្តដោយមានជំនួយគាំទ្រពីប្រភពស្របច្បាប់នានានៅក្នុងខណៈដែលឧស្សាហកម្មពូជដំណាំ កំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ។ ប៉ុន្តែក្នុងគោលដៅរយៈពេលវែង ចាំបាច់ត្រូវមានការបង់ថ្លៃសេវាកម្ម ដើម្បីឆ្លើយតបនឹងការចំណាយផ្ទាល់នៅក្នុងការផ្តល់សេវាកម្មនេះ។

៦៩. ការទទួលបានឥណទាន នៅតែជាឧបសគ្គចម្បងមួយក្នុងវិស័យកសិកម្ម ក៏ដូចជាក្នុងឧស្សាហកម្មពូជដំណាំ ពោលគឺទាំងការវិនិយោគទុន និងឥណទានសម្រាប់ផលិតកម្មតាមរដូវកាល។ តាមរយៈ ការប្រឹក្សាយោបល់ជាមួយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា គ្រឹះស្ថានហិរញ្ញវត្ថុដែលធ្វើសកម្មភាពក្នុងវិស័យកសិកម្ម ត្រូវសិក្សារកដំណោះស្រាយជាយុទ្ធសាស្ត្រលើបញ្ហានេះ ដើម្បីជួយដល់សហគមន៍អ្នកផលិតពូជដំណាំ និងសហគ្រាសខ្នាតតូច ដែលបំពេញការងារបានល្អ និងរក្សាបាននូវអាជីវកម្មពូជ

ដំណាំជាប្រចាំ។ ការផ្តល់ឱកាសឱ្យប្រើប្រាស់ពូជដំណាំស្តុកជាវត្ថុបញ្ចាំសម្រាប់ទទួលបាននូវឥណទានតាមរដូវកាល គឺមានសារៈសំខាន់ចំពោះផលិតករ និងអាជីវករពូជដំណាំ។

## ៣.១១ ការពិចារណាដល់បរិស្ថាន

**៧០.** ការប្រើប្រាស់ប្រភេទពូជសមស្រប និងពូជដំណាំមានគុណភាពល្អ អាចនាំមកនូវប្រាក់ចំណេញជាច្រើនដល់កសិករ និងអ្នកដាំដុះផ្សេងទៀត ហើយពុំមានផលអវិជ្ជមានចំពោះបរិស្ថានឡើយ។ ហានិភ័យតែមួយគត់ដែលអាចកើតមាន គឺការប្រើពូជដំណាំមានដាក់ថ្នាំពុលគីមីសម្រាប់ការពារពូជដំណាំដែលចាំបាច់ត្រូវមានសញ្ញាបញ្ជាក់ឱ្យបានច្បាស់លាស់ ចៀសវាងការយកទៅប្រើមិនត្រឹមត្រូវ។

**៧១.** ការប្រែប្រួលអាកាសធាតុ គឺជាក្តីបារម្ភដ៏ធំមួយនៅកម្ពុជា ដោយសារតែភាពងាយរងគ្រោះនៃដំណាំដែលបង្កដោយគ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់។ ការគំរាមកំហែងនេះ អាចដោះស្រាយបាន តាមរយៈមធ្យោបាយផ្សេងៗ រួមទាំងការរៀបចំឱ្យមានការធានានៅក្នុងការផ្គត់ផ្គង់ទឹកស្រោចស្រព។ ប៉ុន្តែការអភិវឌ្ឍប្រភេទពូជដែលមានអាយុកាលសមស្រប និងមានភាពបន្សាំខ្ពស់ជាមួយនឹងលក្ខខណ្ឌបរិស្ថាន គឺជាកត្តាគន្លឹះយ៉ាងសំខាន់នៅក្នុងប្រព័ន្ធកសិកម្ម ដើម្បីតម្រង់ទិសនៅក្នុងកម្មវិធីបង្កាត់ និងជ្រើសរើសប្រភេទពូជដំណាំឆ្លើយតបនឹងលក្ខខណ្ឌជាក់លាក់តាមប្រព័ន្ធកេ្សត្របរិស្ថាននីមួយៗ។ ដោយសារការគ្រប់គ្រងពូជដំណាំគឺជាយន្តការមួយសម្រាប់ណែនាំប្រភេទពូជថ្មីនៃដំណាំ ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំមួយប្រកបដោយប្រសិទ្ធភាព អាចបញ្ជូនប្រភេទពូជថ្មីៗទៅដល់កសិករ និងអ្នកដាំដុះផ្សេងទៀតបានឆាប់រហ័ស។ តម្រូវការប្រភេទពូជដំណាំដែលធន់នឹងសមាសភាពចង្រៃ និងលក្ខខណ្ឌមិនអំណោយផល ក៏ជាបន្ទុករបស់កម្មវិធីបង្កាត់ និងជ្រើសរើសប្រភេទពូជដំណាំផងដែរ។

**៧២** ការបាត់បង់ជីជាតិដីគឺជាហានិភ័យបរិស្ថានមួយទៀត ដែលចាំបាច់ត្រូវមានវិធានការច្បាស់លាស់ ដើម្បីគ្រប់គ្រង និងកែលម្អគុណភាពដីដែលសឹករេចនោះ។ ការណែនាំឱ្យប្រើប្រភេទដំណាំថ្មីៗអាចជាវិធីសាស្ត្រដោះស្រាយបញ្ហានេះ ហើយជាការទទួលខុសត្រូវរបស់ស្ថាប័នសាធារណៈ ក្នុងការកំណត់ប្រភេទដំណាំសមស្របសម្រាប់ប្រើប្រាស់ និងសម្រាប់ក្រុមហ៊ុនពូជដំណាំឯកជន នៅក្នុងការកំណត់ប្រភពផ្គត់ផ្គង់ពូជដំណាំ។ ដៃគូអភិវឌ្ឍន៍ដែលធ្វើសកម្មភាពក្នុងផ្នែកបរិស្ថាន ក៏មានតួនាទីសំខាន់ក្នុងការចូលរួមអនុវត្តការងារទាំងនេះឱ្យមានប្រសិទ្ធភាពផងដែរ។

**៧៣** ការថែរក្សាឱ្យមានភាពសម្បូរបែបនៃពន្ធុពូជដំណាំនៅក្នុងវិស័យកសិកម្ម គឺជាមូលដ្ឋានគន្លឹះនៅក្នុងការបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ដូច្នេះការអភិរក្សជីវចម្រុះកសិកម្ម នឹងចូលរួមចំណែកធានាសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់កសិករ និងអ្នកដាំដុះផ្សេងទៀត។ នៅពេលដែលមានការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ចាំបាច់ត្រូវធ្វើការតាមដានជាប្រចាំនូវឥទ្ធិពលនៃប្រព័ន្ធផលិតកម្មតាមបែបប្រពលវប្បកម្ម និងឯកវប្បកម្មដំណាំដើម្បីធានាថា ប្រភេទពូជដំណាំដែលជាជីវចម្រុះប្រពៃណីត្រូវបានអភិរក្សនៅក្នុងសហគមន៍។

**៧៤.** ព្រះរាជាណាចក្រកម្ពុជា មានឱកាសទទួលបាននូវផលប្រយោជន៍ពីផលិតផលសរីរាង្គដែលមានការទទួលស្គាល់ ហើយប្រការនេះអាចនាំមកនូវតម្លៃពិសេសនៅលើទីផ្សារ។ ភាគច្រើននៃផលិតកម្មស្រូវប្រពៃណី អាចត្រូវបានចាត់ទុកជាផលិតកម្មសរីរាង្គ ។ ដើម្បីជួយដល់កសិករ និងអ្នកដាំដុះផ្សេងទៀត ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានជំរុញសកម្មភាពនេះ ព្រមទាំងរក្សាអត្តសញ្ញាណផលិតផលរហូតដល់ទីផ្សារ។ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ផលិតផលសរីរាង្គពេញលេញនៅលើទីផ្សារអន្តរជាតិ ចាំបាច់ត្រូវមានការបញ្ជាក់អំពីប្រភពពូជដំណាំដែលប្រើប្រាស់សម្រាប់ធ្វើការដាំដុះ ហើយអគ្គនាយកដ្ឋានកសិកម្មត្រូវគាំទ្រលើការខិតខំប្រឹងប្រែងនេះដើម្បីបំពេញលក្ខខណ្ឌតម្រូវរបស់ទីផ្សារអន្តរជាតិ។

## ៣.១២ សហប្រតិបត្តិការ និងទំនាក់ទំនងអន្តរជាតិ

**៧៥.** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាស្ថាប័នជាតិគ្រប់គ្រងពូជដំណាំ ត្រូវចូលរួមសកម្មភាពរបស់អង្គការអន្តរជាតិ និងតំបន់ជាចាំបាច់ ដើម្បីតាមដាន និងមានវិធានការឆ្លើយតបស្របតាមបច្ចុប្បន្នភាពនៃការអភិវឌ្ឍឧស្សាហកម្មពូជដំណាំអន្តរជាតិ។ ព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមចលនាសុខដុមណីយកម្មលើបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងពូជដំណាំ ក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន ដើម្បីសម្រួលការធ្វើពាណិជ្ជកម្មនៅក្នុងតំបន់ដែលកំពុងមានសន្ទុះរីកចម្រើន។ ព្រះរាជាណាចក្រកម្ពុជា បានបង្កើតរួចជាស្រេចនូវទំនាក់ទំនងពាណិជ្ជកម្មជិតស្និទ្ធ ជាមួយបណ្តាប្រទេសជិតខាងរបស់ខ្លួន ហើយការងារនេះអាចមានឥទ្ធិពលចំពោះការអភិវឌ្ឍឧស្សាហកម្មពូជដំណាំរបស់ជាតិ ដែលត្រូវធ្វើការតាមដាន និងវាយតម្លៃប្រកបដោយការទទួលខុសត្រូវពីសំណាក់ក្រុមប្រឹក្សាជាតិពូជដំណាំ។

**៧៦.** ក្រុមហ៊ុនពូជដំណាំក្នុងស្រុក ត្រូវបានលើកទឹកចិត្តឱ្យចូលរួមជាមួយអង្គការពាក់ព័ន្ធនានានៅក្នុងតំបន់ ដូចជាសមាគមពូជដំណាំអាស៊ី និងប៉ាស៊ីហ្វិក និងជាមួយអង្គការអន្តរជាតិទាំងឡាយដែលធ្វើសកម្មភាពពាក់ព័ន្ធពូជដំណាំ។ នៅពេលដែលសមាគមនៃផលិតករ និងអាជីវករពូជដំណាំត្រូវបានអភិវឌ្ឍ ស្ថាប័នជាតិគ្រប់គ្រងឧស្សាហកម្មពូជដំណាំត្រូវសម្របសម្រួលបង្កើតឱ្យមានជាសមាគមពាណិជ្ជកម្មពូជដំណាំ ដើម្បីមានតំណាងវិស័យឯកជនចូលរួមក្នុងវេទិកាជាតិ តំបន់ និងអន្តរជាតិ។

# ៤. សកម្មភាពជាអាទិភាព

**៧៧.** ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងដើម្បីជំរុញដល់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំឱ្យមានប្រសិទ្ធភាព ស្របតាមគោលនយោបាយនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានដូចខាងក្រោម៖

- បង្កើតអង្គភាពគ្រប់គ្រងពូជដំណាំមួយនៅក្នុងអគ្គនាយកដ្ឋានកសិកម្ម ដើម្បីធ្វើការសម្របសម្រួលរាល់សកម្មភាពពាក់ព័ន្ធនឹងពូជដំណាំ និងព័ត៌មានស្តីពីពូជដំណាំ

- បង្កើតក្រុមប្រឹក្សាជាតិពូជដំណាំតំណាងដោយអ្នកពាក់ព័ន្ធសំខាន់ៗសម្រាប់ផ្តល់ប្រឹក្សាយោបល់ត្រួតពិនិត្យ និងតាមដានលើការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ ដែលអង្គភាពគ្រប់គ្រង ពូជដំណាំដើរតួនាទីជាលេខាធិការដ្ឋាន
- បង្កើតគណៈកម្មាធិការជាតិបញ្ចេញពូជដំណាំ សម្រាប់ធ្វើការសម្រេចចិត្តលើការបញ្ចេញប្រភេទពូជថ្មីនៃដំណាំ និងដើម្បីគ្រប់គ្រងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ
- កំណត់ និងជំរុញប្រព័ន្ធពង្រីកពូជដំណាំដែលមានប្រសិទ្ធភាព ដោយមានការចូលរួមពីស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកដាំដុះ ដើម្បីធានាឱ្យមានការផ្គត់ផ្គង់ពូជដំណាំ ដែលមានគុណភាពល្អបានគ្រប់គ្រាន់
- បង្កើតឱ្យមានប្រព័ន្ធផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ និងធានាឱ្យមាន ធនធានមនុស្ស និងធនធានរូបវន្តទាំងឡាយសម្រាប់អនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើតមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តពូជដំណាំដែលជាផ្នែកមួយនៃមន្ទីរពិសោធន៍ជាតិកសិកម្មសម្រាប់គាំទ្រដល់ការត្រួតពិនិត្យគុណភាពពូជដំណាំដែលស្ថិតនៅក្រោមប្រព័ន្ធផ្តល់វិញ្ញាបនបត្រ និងសម្រាប់តាមដានគុណភាពពូជដំណាំដែលចរាចរណ៍នៅលើទីផ្សារ
- រៀបចំគោលការណ៍ណែនាំបច្ចេកទេសចាំបាច់នានាសម្រាប់អនុវត្តនៅលើទីវាល និងនៅមន្ទីរពិសោធន៍ស្របតាមស្តង់ដារអន្តរជាតិ
- បន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដែលត្រូវការសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍប្រភេទពូជថ្មីៗ និងការត្រួតពិនិត្យគុណភាពពូជដំណាំឱ្យមានប្រសិទ្ធភាពល្អ
- ប្រមូលបទពិសោធន៍របស់ក្រុមអ្នកផលិតពូជដំណាំ និងសហគមន៍ផលិតពូជដំណាំដើម្បីរៀបចំគោលការណ៍ណែនាំស្តង់ដារ សម្រាប់ការគ្រប់គ្រងក្រុមឬសហគមន៍ផលិតពូជដំណាំប្រកបដោយនិរន្តភាព
- ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមអ្នកផលិតពូជដំណាំ អំពីកិច្ចប្រតិបត្តិល្អនៅក្នុងការផលិតពូជដំណាំ និងផ្តល់ការទទួលស្គាល់ជាផ្លូវការចំពោះផលិតករណា ដែលបានបំពេញគ្រប់លក្ខខណ្ឌចាំបាច់
- បង្កើតប្រព័ន្ធចុះបញ្ជីប្រភេទពូជដំណាំដែលមានភាពងាយស្រួល ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិចសម្រាប់ឱ្យអ្នកស្នើសុំ អាចចុះឈ្មោះ ប្រភេទពូជ និងផ្តល់ព័ត៌មានអំពីពូជដំណាំដល់អ្នកប្រើប្រាស់
- ជំរុញឱ្យមានការដាក់បញ្ចូលមុខវិជ្ជាពាក់ព័ន្ធនឹងឧស្សាហកម្មពូជដំណាំទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំ និងស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ

- សម្របសម្រួលជាមួយនឹងស្ថាប័នហិរញ្ញវត្ថុ វិស័យឯកជន និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើនការវិនិយោគលើការស្រាវជ្រាវរកប្រភេទពូជដំណាំថ្មីៗ និងបង្កើតឱ្យមានឧស្សាហកម្មពូជដំណាំសម្បូរបែបប្រកបដោយការប្រកួតប្រជែងផែនការសកម្មភាពជាអាទិភាពសម្រាប់អនុវត្តគោលនយោបាយនេះ មានចែងនៅក្នុងឧបសម្ព័ន្ធនៃគោលនយោបាយនេះ។

## ៥. ការត្រួតពិនិត្យ និងវាយតម្លៃ

**៧៨.** ក្រុមប្រឹក្សាជាតិពូជដំណាំ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ និងតាមដានការអនុវត្តការងាររបស់គ្រប់តួអង្គពាក់ព័ន្ធទាក់ទិននឹងការងារស្រាវជ្រាវ ផលិតកម្ម អាជីវកម្ម ការត្រួតពិនិត្យគុណភាព និងការប្រើប្រាស់ពូជដំណាំ។ កិច្ចការរបស់ក្រុមប្រឹក្សាជាតិនេះ ត្រូវបានគាំទ្រដោយអង្គភាពគ្រប់គ្រងពូជដំណាំដែលជាអ្នកផ្តល់ព័ត៌មាន និងស្ថិតិសំខាន់ៗទាក់ទិននឹងការវិវត្តនៃឧស្សាហកម្មពូជដំណាំនៅកម្ពុជា និងអន្តរជាតិ។

**៧៩.** អង្គភាពគ្រប់គ្រងពូជដំណាំ ត្រូវសហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាតាមរយៈការរៀបចំវេទិកាពិភាក្សាជាទៀងទាត់ ដើម្បីពិនិត្យទៅលើការគាំទ្រ និងការចូលរួមរបស់គ្រប់តួអង្គក្នុងការអភិវឌ្ឍឧស្សាហកម្មពូជដំណាំ និងវាយតម្លៃគុណភាពពូជដំណាំដែលផលិតដោយផលិតករពូជដំណាំនានា និងផ្គត់ផ្គង់ដោយអាជីវករ។ ផ្អែកទៅលើលទ្ធផលនៃវេទិកានេះ អង្គភាពគ្រប់គ្រងពូជដំណាំ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនទៅក្រុមប្រឹក្សាជាតិពូជដំណាំ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានវិធានការ។

**៨០.** គោលនយោបាយនេះ គឺជាឯកសារដែលផ្តល់គោលការណ៍ណែនាំចំពោះរាល់អ្នកពាក់ព័ន្ធ ហើយអាចធ្វើការកែសម្រួលជាបន្តបន្ទាប់ស្របតាមស្ថានភាពអភិវឌ្ឍន៍នៃឧស្សាហកម្មពូជដំណាំពីព្រោះឧស្សាហកម្មនេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការប្រែប្រួលរបស់ទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។ គោលនយោបាយនេះនឹងត្រូវធ្វើការពិនិត្យឡើងវិញទាំងស្រុងនៅក្នុងរយៈពេលប្រាំឆ្នាំតាមការចាំបាច់ គិតចាប់ពីកាលបរិច្ឆេទអនុម័តនៅគ្រាដំបូង។

## ៦. សន្និដ្ឋាន

**៨១.** ទោះបីជាពូជដំណាំគ្រាន់តែជាធាតុចូលជាក់លាក់មួយនៅក្នុងផលិតកម្មកសិកម្មក៏ដោយ ក៏ពូជដំណាំមានឥទ្ធិពលខ្លាំងទៅលើផលិតកម្ម និងទីផ្សារ។ ពូជដំណាំជាមធ្យោបាយមួយដែលនាំប្រភេទពូជថ្មីៗពីកន្លែងស្រាវជ្រាវទៅដល់អ្នកដាំដុះ និងមានឥទ្ធិពលទៅលើការដុះលូតលាស់ ការកំណត់នូវគុណភាពផលិតផល និងទិន្នផលនៃការដាំដុះដំណាំនោះផងដែរ។ ដោយហេតុថាវិស័យកសិកម្មនៅកម្ពុជាមានការវិវត្តឡើង ហើយសកម្មភាពមួយចំនួនដូចជា ការធ្វើពាណិជ្ជកម្ម ការធ្វើប្រពលវប្បកម្ម និងពិពិធកម្មនៃផលិតកម្មក៏កាន់តែមានសារៈសំខាន់ខ្លាំងឡើងដែរ។ សកម្មភាពទាំងអស់នេះ ត្រូវបានកំណត់ជាធាតុចូលគន្លឹះរួចជាស្រេច នៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។ បញ្ហាសំខាន់មួយទៀត គឺការគំរាមកំហែងបង្កឡើងដោយបម្រែបម្រួលអាកាសធាតុដែលអាចមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើផលិតកម្មកសិកម្ម ដោយសារតែភាពងាយរងគ្រោះរបស់កម្ពុជាដែលបណ្តាល មកពីគ្រោះរាំងស្ងួត ទឹកជំនន់ និងការបាត់បង់គុណភាពដី។

៨២. ដើម្បីដោះស្រាយសេចក្តីត្រូវការដ៏ស្មុគស្មាញទាំងនេះ ចាំបាច់ត្រូវមានប្រព័ន្ធផ្គត់ផ្គង់ពូជដំណាំមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។ កន្លងមក ទោះបីជាមានអន្តរាគមន៍ជាច្រើន ដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្តី ក៏នៅតែមានកង្វះខាតលើការងារសម្របសម្រួលរវាងអ្នកពាក់ព័ន្ធទាំងឡាយ។ គោលនយោបាយនេះនឹងបំពេញនូវភាពខ្វះចន្លោះក្នុងការងារសម្របសម្រួលកន្លងមក និងបង្កើតឱ្យមានឧស្សាហកម្មពូជដំណាំមួយដែលមានគោលការណ៍ច្បាស់លាស់ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ដើម្បីសម្រេចបានគោលដៅនេះ តម្រូវឱ្យមានកិច្ចសហការរវាងវិស័យសាធារណៈ និងឯកជន ហើយភារកិច្ចសំខាន់របស់រាជរដ្ឋាភិបាល គឺបង្កើតបរិយាកាសវិនិយោគអំណោយផល ដែលអនុញ្ញាតឱ្យវិស័យឯកជនអាចបំពេញតួនាទីក្នុងផលិតកម្ម និងទីផ្សារពូជដំណាំ ដោយប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួន។

៨៣. គោលនយោបាយនេះ រួមជាមួយច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងបទដ្ឋានគតិយុត្តិក្រោមច្បាប់នេះ អាចផ្តល់ក្របខ័ណ្ឌគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំទំនើប ដែលអាចសម្របតាមការប្រែប្រួលដែលកើតមានក្នុងវិស័យកសិកម្មកម្ពុជា និងនៅលើទីផ្សារពិភពលោក។

៨៤. ក្រោយពេលអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្មត្រូវបោះពុម្ព ផ្សព្វផ្សាយ និងបញ្ជ្រាបគោលនយោបាយនេះឱ្យបានទូលំទូលាយដើម្បីឱ្យមានការយល់ដឹងដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលមានបំណងចូលរួមនៅក្នុងការងារពូជដំណាំនៅកម្ពុជា។

## ៧. វាក្យស័ព្ទ

៨៥. ពាក្យគន្លឹះសំខាន់ៗដែលប្រើប្រាស់សម្រាប់គោលនយោបាយនេះ ត្រូវបានឱ្យនិយមន័យដូចខាងក្រោម៖

- **ប្រភេទពូជ** (Variety): សំដៅដល់ក្រុម ឬប្រភេទដំណាំដែលមានចរិតលក្ខណៈដូចគ្នា ហើយដែលខុសពីក្រុម ឬប្រភេទដំណាំដទៃទៀត ទោះក្នុងលក្ខណៈណាមួយក៏ដោយ។
- **ពូជដំណាំ** (Seed): សំដៅដល់រាល់សរីរាង្គពូជក្នុងទម្រង់ជាគ្រាប់ ដើម ផ្លែ មែក មើម ឬសសំបក ស្ព័រ កោសិកា ឬជាលិកា ដែលប្រើប្រាស់សម្រាប់ធ្វើការដាំដុះក្នុងផលិតកម្ម ឬពិសោធន៍ស្រាវជ្រាវ។
- **ពូជដំណាំមេ** (Nucleus Seed): សំដៅដល់ប្រភេទពូជដំណាំដែលត្រូវបានផលិត និងរក្សាទុកដោយរុក្ខជម្រើសវិទូ ហើយមិនមែនជាពូជដំណាំសម្រាប់ការធ្វើពាណិជ្ជកម្មទេ។
- **ពូជដំណាំជម្រើសវិទូ** (Breeder Seed): សំដៅដល់ប្រភេទពូជដំណាំដែលត្រូវបានផលិតដោយរុក្ខជម្រើសវិទូដែលប្រើប្រាស់ពូជដំណាំមេ និងដាំជាជួរ ដោយប្រើក្បួនស្រាវដែលបានប្រមូលពីពូជដំណាំមេ និងទទួលស្គាល់ពីស្ថាប័នដើមដែលជាអ្នកបង្កើតប្រភេទពូជមុនគេ។ ពូជដំណាំ

ជម្រើសវិទូ ជាប្រភពសម្រាប់ផលិតពូជដំណាំនៃចំណាត់ថ្នាក់ដទៃទៀត ជាពិសេសសម្រាប់ផលិតកម្មនៃពូជដំណាំគ្រឹះ។

- **ពូជដំណាំគ្រឹះ** (Foundation Seed): សំដៅដល់ពូជដំណាំដែលត្រូវបានផលិតដោយរុក្ខជម្រើសវិទូដែលប្រើប្រាស់ពូជដំណាំជម្រើសវិទូ ដោយត្រូវដាំជាជួរ ១ដើម ឬ១គ្រាប់ក្នុង១គុម្ព ក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់ម្ចាស់ពូជ។ ពូជដំណាំគ្រឹះ ត្រូវបានផលិតក្រោមវិធានដែលបង្កើតដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំក្នុងគោលបំណងរក្សាភាពសុទ្ធពន្ធុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។
- **ពូជដំណាំចុះបញ្ជី** (Registered Seed): សំដៅដល់ ពូជដំណាំដែលត្រូវបានផលិតដោយប្រើប្រាស់ពូជដំណាំគ្រឹះដោយត្រូវដាំជាជួរ ក្រោមវិធានដែលមានការទទួលស្គាល់ពីអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពន្ធុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។
- **ពូជដំណាំវិញ្ញាបនបត្រ** (Certified Seed): សំដៅដល់ពូជដំណាំដែលត្រូវបានផលិតដោយប្រើប្រាស់ពូជដំណាំចុះបញ្ជី ក្រោមវិធានដែលមានការទទួលស្គាល់ពីអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពន្ធុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។
- **អ្នកបង្កាត់ពូជដំណាំ ឬរុក្ខជម្រើសវិទូ** (Plant Breeder): សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការអភិរក្ស ការអភិវឌ្ឍ ការបង្កាត់ ការពិសោធសាកល្បង ការជ្រើសរើស និងការបញ្ចេញប្រភេទពូជដំណាំ។
- **ពូជអ៊ីប្រ៊ីត** (Hybrid): សំដៅដល់ប្រភេទពូជដែលជាឯកត្តៈជំនាន់ទី១ បានមកពីការបង្កាត់រវាងមេបាដែលជាពូជស្រឡាយបង្កាត់ក្នុង ហើយមិនអាចដាំបន្តទៀតបាននៅជំនាន់បន្ទាប់ក្រោយប្រមូលផល។
- **ពូជបសិដ្ឋកម្ម** (Improved Variety): សំដៅដល់ប្រភេទពូជដែលបានធ្វើឱ្យប្រសើរឡើងនូវចរិតលក្ខណៈមួយចំនួនតាមវិធីសាស្ត្ររុក្ខជម្រើសវិទ្យា។
- **ពូជបម្លែងពន្ធុ** (Transgenic Variety-GMO): សំដៅដល់ប្រភេទពូជដែលត្រូវបានបង្កើតឡើងតាមរយៈវិស្វកម្មពន្ធុដោយធ្វើការញែក និងផ្ទេរអង្គធាតុក្រូម៉ូសូម (DNA) នៃសរីរាង្គមួយទៅសរីរាង្គមួយទៀត ដើម្បីអភិវឌ្ឍប្រភេទពូជថ្មី ដែលមិនធ្លាប់មានក្នុងធម្មជាតិ។

**ពូជដំណាំកាន់តែល្អ ផ្តល់ទិន្នផលកាន់តែប្រសើរ**

Better Seed Better Yield

## ឧបសម្ព័ន្ធ៖ សកម្មភាពជាអាទិភាព

| ល.រ | វិធានការ | សកម្មភាព | សម្គាល់ |
|---|---|---|---|
| **វិធានការរយៈពេលខ្លី** | | | |
| ១ | ការសម្របសម្រួលរាល់សកម្មភាពពាក់ព័ន្ធនឹងពូជដំណាំនៅកម្ពុជា | បង្កើតអង្គភាពគ្រប់គ្រងពូជដំណាំដែលមានភារកិច្ចទទួលខុសត្រូវទូទៅលើការងារគ្រប់គ្រងពូជដំណាំ | រាល់គម្រោងអភិវឌ្ឍពូជដំណាំត្រូវមានទំនាក់ទំនង និងការសម្របសម្រួលជាមួយអង្គភាពនេះ |
| ២ | ការត្រួតពិនិត្យជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍពូជដំណាំ | បង្កើតក្រុមប្រឹក្សាជាតិពូជដំណាំដើម្បីត្រួតពិនិត្យវឌ្ឍនភាពនិងតម្រង់ទិសការអភិវឌ្ឍឧស្សាហកម្ម ពូជដំណាំ | ក្រុមប្រឹក្សានេះត្រូវមានតំណាងមកពីស្ថាប័នពាក់ព័ន្ធសំខាន់ៗចូលរួមជាសមាជិក ហើយអង្គភាពគ្រប់គ្រងពូជដំណាំបំពេញតួនាទីជាលេខាធិការដ្ឋាន |
| ៣ | ការបង្កើតបទដ្ឋានគតិយុត្តសម្រាប់ពូជដំណាំ | រៀបចំបទដ្ឋានគតិយុត្តស្ថិតក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំនិងអនុវត្តឱ្យមានប្រសិទ្ធភាព | អង្គភាពគ្រប់គ្រងពូជដំណាំជាអ្នកទទួលបន្ទុកក្នុងការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ |
| ៤ | ការបង្កើនសមត្ថភាពធ្វើតេស្តពូជដំណាំប្រកបដោយគុណភាពនិងប្រសិទ្ធភាពខ្ពស់ | បង្កើតមន្ទីរពិសោធន៍ធ្វើតេស្តពូជដំណាំជាផ្នែកមួយនៃមន្ទីរពិសោធន៍ជាតិកសិកម្ម | ត្រូវជ្រើសរើសមន្ត្រីដែលមានជំនាញ និងរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់ប្រតិបត្តិការ |
| ៥ | ការរៀបចំប្រព័ន្ធវាយតម្លៃ និងចុះបញ្ជីប្រភេទពូជដំណាំជាផ្លូវការ | បង្កើតគណៈកម្មាធិការជាតិបញ្ចេញពូជដំណាំ និងកំណត់នីតិវិធីប្រតិបត្តិការឱ្យបានច្បាស់លាស់ | គណៈកម្មាធិការនេះត្រូវមានតំណាងមកពីស្ថាប័នពាក់ព័ន្ធសំខាន់ៗហើយអង្គភាពគ្រប់គ្រងពូជដំណាំបំពេញតួនាទីជាលេខាធិការដ្ឋាន |
| ៦ | ការអភិវឌ្ឍបញ្ជីប្រភេទពូជដំណាំរបស់ជាតិ | បង្កើតនីតិវិធីសម្រាប់ធ្វើតេស្ត និងកំណត់លក្ខណវិនិច្ឆ័យសម្រាប់ចុះបញ្ជីប្រភេទពូជថ្មីនៃដំណាំ | ប្រភេទពូជដែលបានបញ្ចេញឱ្យប្រើប្រាស់ត្រូវបញ្ចូលក្នុងបញ្ជីដោយគណៈកម្មាធិការជាតិបញ្ចេញប្រភេទពូជដំណាំ ដែលជាអ្នកពិនិត្យ និងសម្រេចលើការងារនេះ |

| | | | |
|---|---|---|---|
| ៧ | ការកំណត់ការទទួលខុសត្រូវក្នុងប្រព័ន្ធផលិតកម្មពូជដំណាំ | រៀបចំផែនការសកម្មភាពសម្រាប់ផលិតកម្មពូជដំណាំនៃមុខដំណាំសំខាន់ៗ | ត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់អំពីបញ្ហា និងរកដំណោះស្រាយសមស្រប ជាពិសេសក្នុងផលិតកម្មពូជដំណាំពូជគ្រឹះ ដើម្បីឱ្យមានបរិមាណគ្រប់គ្រាន់ និងគុណភាពល្អ |
| ៨ | ការពង្រឹងការគ្រប់គ្រង និងផ្គត់ផ្គង់ពូជដំណាំ ជាពិសេសពូជដំណាំគ្រឹះ | ពិនិត្យនិងតាមដានផលិតកម្មពូជដំណាំ ជាពិសេសពូជដំណាំគ្រឹះ ដើម្បីបង្កើនការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការ | ត្រួតពិនិត្យការផលិតគ្រាប់ពូជដំណាំ រួមទាំងផលិតកម្មពូជដំណាំគ្រឹះ ដោយអនុលោមតាមបទដ្ឋានបច្ចេកទេស និងច្បាប់ ដើម្បីធានាបរិមាណ និងគុណភាព |
| ៩ | ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សដែលត្រូវការសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍប្រភេទពូជដំណាំ | បន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សដែលត្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍប្រភេទពូជថ្មីៗ និងការត្រួតពិនិត្យគុណភាពពូជដំណាំឱ្យមានប្រសិទ្ធភាពខ្ពស់ | ការពង្រឹងសមត្ថភាពនេះ ត្រូវធ្វើឡើងដោយគ្រប់អង្គភាពជំនាញ និងភាគីពាក់ព័ន្ធទាំងអស់ រួមទាំងស្ថាប័នសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ |
| **វិធានការរយៈពេលមធ្យម** | | | |
| ១០ | គោលនយោបាយស្ដីពីពូជបម្លែងពន្ធុ (GMO) | កំណត់បទដ្ឋានគតិយុត្ត និងនីតិវិធីវាយតម្លៃសម្រាប់ប្រភេទពូជដំណាំបម្លែងពន្ធុ ដោយពិភាក្សាជាមួយភាគីពាក់ព័ន្ធផ្សេងៗ | តាមដាន និងពិនិត្យស្ថានភាពនៃការប្រើប្រាស់ពូជដំណាំ GMOs នៅក្នុងបណ្ដាប្រទេសជិតខាង តំបន់ និងពិភពលោក |
| ១១ | តម្រូវការប្រភេទពូជថ្មីៗ នៃដំណាំជាអាទិភាព ជាពិសេស ពូជស្រូវដែលមានអាយុកាលខ្លី និងមានគុណភាពខ្ពស់ | ជំរុញកម្មវិធីបង្កាត់ និងជ្រើសរើសប្រភេទពូជថ្មីៗនៃដំណាំ ជាពិសេសពូជស្រូវ ដើម្បីកំណត់អាទិភាពនិងយុទ្ធសាស្ត្រផ្ដល់ថវិការយៈពេល៥ឆ្នាំ | ផ្ដល់ការលើកទឹកចិត្តនិងមធ្យោបាយបន្ថែម ដើម្បីបង្កើនបរិមាណនៃប្រភេទពូជសម្រាប់ជ្រើសរើសនិងបញ្ចេញឱ្យប្រើប្រាស់ស្របតាមបរិបទនៃការប្រែប្រួលអាកាសធាតុនិងតម្រូវការទីផ្សារ |
| ១២ | ការត្រួតពិនិត្យគុណភាពពូជដំណាំនៅលើទីផ្សារ | រៀបចំវគ្គបណ្ដុះបណ្ដាលដល់អ្នកធ្វើអធិការកិច្ចពូជដំណាំអំពីវិធីសាស្ត្រយកសំណាក និងការត្រួតពិនិត្យគុណភាពពូជដំណាំ | ការវាយតម្លៃគុណភាពពូជដំណាំ គឺផ្អែកលើមន្ទីរពិសោធន៍ពូជដំណាំ និងសមត្ថភាពរបស់មន្ត្រីអធិការកិច្ច ដោយអនុវត្តស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តក្រោមច្បាប់ |
| ១៣ | ការគាំទ្រថវិកាសម្រាប់ការ | បង្កើតក្រុមការងារមួយដោយមានស្ថាប័ន | ត្រូវមានយន្តការផ្ដល់ការលើកទឹកចិត្តសម្រាប់សហគមន៍កសិកម្ម |

| | | | |
|---|---|---|---|
| | វិនិយោគលើពូជដំណាំ | ថវិកាចូលរួម ដើម្បីទទួលបានថវិកាគាំទ្រសម្រាប់វិនិយោគ ដោយផ្ដល់អាទិភាពដល់សកម្មភាពទាក់ទងនឹងពូជដំណាំ | ក្រុមហ៊ុនវិស័យឯកជន រួមទាំងរោងម៉ាស៊ីនកិនស្រូវ ដើម្បីវិនិយោគលើផលិតកម្មពូជដំណាំមានគុណភាពល្អ |
| ១៤ | ការពង្រឹងប្រព័ន្ធផលិតកម្មពូជដំណាំក្នុងស្រុក | ប្រមូលព័ត៌មាន និងកំណត់ក្រុមកសិករឬសហគមន៍ផលិតពូជដំណាំ និងរៀបចំក្រុមប្រតិបត្តិសម្រាប់ផលិតកម្ម និងការគ្រប់គ្រងពូជដំណាំឱ្យបានច្បាស់លាស់ | សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត និងអង្គការក្រៅរដ្ឋាភិបាលនានាក្នុងការប្រមូលព័ត៌មាន និងរៀបចំឯកសារបច្ចេកទេស និងនីតិវិធីគ្រប់គ្រងប្រព័ន្ធផលិតកម្មពូជដំណាំ |
| ១៥ | ផលិតកម្មពូជដំណាំនៅតាមមូលដ្ឋាន | រៀបចំគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ត្រួតពិនិត្យគុណភាពពូជដំណាំ និងការដាក់ស្លាកសញ្ញា ដោយផលិតករតាមមូលដ្ឋាន | លើកទឹកចិត្តដល់ក្រុមផលិតពូជដំណាំដែលមានភាពជោគជ័យឱ្យក្លាយជាសហគ្រាសខ្នាតតូច និងខ្នាតមធ្យម |
| ១៦ | ការសម្របសម្រួលការនាំចេញនាំចូល និងលុបបំបាត់ការរត់ពន្ធខុសច្បាប់ | ពង្រឹងបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធ ជាពិសេសភូតគាមអនាម័យ ដើម្បីសម្រួលការធ្វើពាណិជ្ជកម្មពូជដំណាំ | ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធរួមទាំង នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ និងក្រសួងពាណិជ្ជកម្មផងដែរ |
| ១៧ | ការអនុវត្តផលិតកម្មពូជដំណាំតាមកិច្ចសន្យា | ពង្រឹងការអនុវត្តបទដ្ឋានគតិយុត្ត ដើម្បីជំរុញការផលិតពូជដំណាំ តាមកិច្ចសន្យារវាងផលិតករ និងអ្នកចែកចាយ-ប្រើប្រាស់ | តម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ រួមទាំងវិស័យឯកជន និងអង្គការកសិករ |
| ១៨ | ការកែលម្អគុណភាពពូជដំណាំដែលរក្សាទុកដោយកសិករ | សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ដើម្បីផលិតឯកសារបង្រៀនកសិករស្ដីពីការសម្រឹតសម្រាំង និងរក្សាពូជដំណាំទុកដោយខ្លួនឯង | ពិនិត្យ និងកែលម្អឯកសារបណ្ដុះបណ្ដាលដែលមានស្រាប់ពីគម្រោងមុនៗ និងជំរុញការបណ្ដុះបណ្ដាលកសិករឱ្យបានទូលំទូលាយ |

| វិធានការសម្រាប់រយៈពេលវែង | | | |
|---|---|---|---|
| ១៩ | ការគាំទ្រដល់ការធ្វើពិពិធកម្មដំណាំ និងអាហារូបត្ថម្ភគ្រួសារ | ផ្តោតការយកចិត្តទុកដាក់ទៅលើការជំរុញផលិតកម្មពូជដំណាំច្រើនប្រភេទដោយក្រុមកសិករដើម្បីបង្កើនការផ្គត់ផ្គង់ | សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ត្រូវចូលរួមក្នុងការជំរុញផលិតកម្មពូជដំណាំតាមគ្រួសារកសិករ ឬនៅកម្រិតសហគមន៍ |
| ២០ | ការគាំទ្រផលិតកម្មដំណាំបន្លែ និងទីផ្សារ | បង្កើតទិន្នន័យព័ត៌មានគ្រឹះស្តីពីប្រភេទពូជដំណាំបន្លែដែលកំពុងពេញនិយមប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានដល់មន្ត្រីផ្សព្វផ្សាយ និងមន្ត្រីគម្រោងអភិវឌ្ឍផ្សេងៗ | អ្នកនាំចូលពូជដំណាំបន្លែ និងភាគីពាក់ព័ន្ធដែលគាំទ្រផ្នែកទីផ្សារត្រូវសហការជាមួយសមត្ថកិច្ចជំនាញ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍និងវិស័យឯកជន ដើម្បីអនុវត្តការងារនេះ ឱ្យមានប្រសិទ្ធភាព |
| ២១ | ការកែលម្អបរិយាកាសវិនិយោគសម្រាប់ឧស្សាហកម្មពូជដំណាំ | សិក្សាស្រាវជ្រាវពីកត្តាវិជ្ជមាន និងអវិជ្ជមានដែលប៉ះពាល់ដល់ការវិនិយោគទុនក្នុងស្រុក និងអន្តរជាតិ ដើម្បីកែលម្អគោលនយោបាយ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធសំដៅលើកទឹកចិត្តដល់ការវិនិយោគទុនក្នុងឧស្សាហកម្មពូជដំណាំ | រៀបចំវេទិកាពិគ្រោះយោបល់ថ្នាក់ជាតិប្រចាំឆ្នាំសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីពិភាក្សាកំណត់បញ្ហាទាក់ទងនឹងឧស្សាហកម្មពូជដំណាំ និងស្វែងរកដំណោះស្រាយសំដៅលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មពូជដំណាំនៅកម្ពុជា។ |

KINGDOM OF CAMBODIA
Nation Religion King
*****

Ministry of Agriculture, Forestry and Fisheries

# Seed Policy for Cambodia



December 2016

## Acknowledgement

This book has been published under a funding support from the Australian Government through Cambodia Agricultural Value Chain (CAVAC) program.

Australian Aid

CAVAC Innovation In Agriculture

## CONTENT


Preface i

1. INTRODUCTION 1

1.1. Current Status of the Seed Industry 2

1.2. Key Constraints and Challenges for the Seed Industry 3

2. VISION, GOAL AND OBJECTIVES 4

2.1. Vision 4

2.2. Goal 4

2.3. Objectives 4

3. STRATEGY 4

3.1. Management of the Seed Sector 5

3.2. Variety Development 5

3.3. Variety Testing and Registration 6

3.4. Plant Variety Protection 7

3.5. Transgenic Varieties (also known as GMOs) 7

3.6. Seed Production and Supply 7

3.7. Training and Extension 10

3.8. Import and Export of Seeds 11

3.9. Regulation of the Seed Industry 11

3.10. Financing the Seed Industry 12

3.11. Environmental Considerations 13

3.12. International Cooperation and Networking 14

4. PRIORITY ACTIONS TO IMPLEMENT THE POLICY 14

5. MONITORING AND EVALUATION 15

6. CONCLUSIONS 15

7. TERMINOLOGY 16

# CONTENT


Preface i

1. INTRODUCTION 1

  1.1. Current Status of the Seed Industry 2

  1.2. Key Constraints and Challenges for the Seed Industry 3

2. VISION, GOAL AND OBJECTIVES 4

  2.1. Vision 4

  2.2. Goal 4

  2.3. Objectives 4

3. STRATEGY 4

  3.1. Management of the Seed Sector 5

  3.2. Variety Development 5

  3.3. Variety Testing and Registration 6

  3.4. Plant Variety Protection 7

  3.5. Transgenic Varieties (also known as GMOs) 7

  3.6. Seed Production and Supply 7

  3.7. Training and Extension 10

  3.8. Import and Export of Seeds 11

  3.9. Regulation of the Seed Industry 11

  3.10. Financing the Seed Industry 12

  3.11. Environmental Considerations 13

  3.12. International Cooperation and Networking 14

4. PRIORITY ACTIONS TO IMPLEMENT THE POLICY 14

5. MONITORING AND EVALUATION 15

6. CONCLUSIONS 15

7. TERMINOLOGY 16

## PREFACE

The agricultural sector of Cambodia is currently in transformation from a family-based extensive production relying on the existing natural resources and using inputs in a traditional way towards a new stage focusing on intensive agricultural production applying modern technologies in all steps along the value chain. Agricultural development has been responding to a vision in which the Royal Government of Cambodia (RGC) has set a strategic goal to enhance agricultural productivity, diversification and commercialization. To achieve this, it is necessary to strengthen the productive capacity of existing land by focusing on well-coordinated interventions between relevant sectors. Key interventions will include better technical services, using inputs more effectively based on technical recommendations, increasing mechanisation and the construction and maintenance of rural infrastructure such as irrigation systems, electricity supply and modern communication technologies. Mechanisms must also be found to provide rural credit, strengthen agricultural marketing, establish agricultural cooperatives and improve land management. The Policy Paper on the Promotion of Paddy Production and Rice Export clearly reflected the RGC's efforts to achieve the above goal by promoting the implementation of necessary measures in the value chain. These have included research, especially the dissemination of rice varieties with good quality and high market demand, improved paddy collection and rice processing capacity, support to credit, improved trade facilitation system, and market research to strengthen competitiveness in the regional and international markets.

These changing stages bring new knowledge for growers who are interested in using high quality seeds to increase their production and ensure high quality produce. Many examples have shown that seed is the starting point in the production chain and it is an important input that can help growers to produce higher yield and better quality of the harvested products.

The Ministry of Agriculture, Forestry and Fisheries (MAFF) has prepared this policy as a framework for the development of the seed industry in Cambodia. This is a key part of the RGCs wider strategy to increase productivity and ensure food security, consistent with other agricultural and rural development initiatives. This policy is based on a long-term vision for the seed industry, which must be implemented together with the Law on Seed Management and Plant Breeder's Rights. It is a mechanism for responding to the needs of all relevant stakeholders in the agricultural sector, taking account of the challenges posed by climate change and the requirements of regional and international markets. Another important objective of this policy is to ensure that growers are able to access improved varieties and high quality seeds through a reliable supply chain and at an affordable price. In order to realise this, it is important to create a favourable environment for private sector investment in the seed industry, enabling a diverse seed

supply chain that will provide greater choice of varieties to farmers and other growers from reliable seed suppliers.

The first draft of this Seed Policy was prepared in 2011 by the General Directorate of Agriculture (GDA) of MAFF in collaboration with the European Union Food Facility Project implemented by the Food and Agriculture Organization of the United Nations (FAO). Further revisions were undertaken during 2012 by a technical working group of GDA, supported by the USAID HARVEST Program. As part of this revision process, two national stakeholder workshops were held, with the participation of provincial line departments of the government, agriculture training and research institutions, seed producing companies and NGOs. Comments and recommendations from these consultations were incorporated into a second draft in 2013. With support of the ADB Climate-Resilient Rice Commercialisation Sector Development Program (Rice SDP) and active participation and contribution from line departments of MAFF as well as other relevant stakeholders, the final version of this Seed Policy was prepared in October 2016.

The MAFF is fully committed to leading this seed policy and encourages all concerned stakeholders including public institutions, private sector, development partners, grower's community and farmers to jointly support and actively participate in its implementation. The MAFF firmly believes that this policy will bring fruitful results for enhancing agricultural development and increasing national economic growth while at the same time reducing poverty and achieving the reform goal for sustainable development under the wise leadership of **Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia**.

Phnom Penh, 30 December 2016

**Minister**

**Ministry of Agriculture, Forestry and Fisheries**

*Signature and stamp*

**Veng Sakhon**

## 1. INTRODUCTION

1. The RGC recognizes the supreme importance of agriculture for maintaining food security and promoting national economic development. Rice provides the foundation of the rural economy and the government demonstrated its support to this crop through the "Policy Paper on the Promotion of Paddy Production and Rice Export" published in 2010. Both paddy production and rice exports have risen steadily during the last six years after the above policy was put in place, although the actual volume exported has still not met the planned target. Cambodia has the advantage of being an exporter of grain at a time when concerns about global food supply are increasing. It is essential to maintain and strengthen this position both for national food security and for economic development.

2. The use of good quality seed is one of the most important factors for increasing agricultural productivity and it can benefit both small and large-scale farmers. Seed are also the input by which improved varieties are delivered to farmers to enhance productivity and quality, bringing more economic gains. In addition, seed production and marketing can provide income-generating opportunities for small businesses in the rural areas.

3. As farmers and other growers shift from household subsistence towards commercial production for the market, they become more concerned about the quality of the seed they use. In Cambodia, the lack of good quality seed is frequently identified as a constraint for improving the uniformity of paddy that mills receive for processing. This emphasizes the fact that seeds are the start of the value chain and efforts to improve the quality of farmers' outputs must begin with the seed that they sow. The same applies to other crops in which the quality of the produce is a key requirement for selling into an organized marketing system that requires consistent quality.

4. To support the development of the seed sector, the Law on Seed Management and Plant Breeders' Rights was adopted in April 2008 to provide a legal basis for the seed trade and for plant variety protection. Subsequently, sub-decree number 118 (November 2008) assigned responsibility for seed management to the General Directorate of Agriculture (GDA). It is therefore the task of GDA to effectively implement this law and various regulations approved by MAFF.

5. While rice seed is the highest priority because of its importance in the national economy and culture, other crops seeds and planting materials are also within the scope of this policy. All parts of the seed supply chain are covered from the breeding and introduction of new varieties to the production, marketing and use of seeds. The policy also reflects the needs of processors and exporters, as well as domestic consumers. It is intended to address all different elements in the seed supply system according to their specific problems and needs.

6. The preparation of this policy as a framework to guide the overall development of the seed industry forms part of the wider strategy of the Government for ensuring food

security and increasing agricultural productivity. The Policy and the Law on Seed Management and Plant Breeders' Rights should be implemented together as tools for developing an efficient seed industry that meets the needs of farmers and other stakeholders. This policy is consistent with other strategic documents relating to the development of agriculture and the rural sector generally.

7. The major goal of this policy is to ensure that farmers have access to high quality seeds and a range of varieties through the most reliable and economic supply channels. To achieve this goal, it is necessary to create an environment that is favorable for the development of a more diverse commercial seed industry, which will provide greater choice to farmers and other stakeholders in terms of quality, varieties and suppliers so that the productive potential of the land, and of Cambodian farmers, can be fully realized.

### 1.1 Current Status of the Seed Industry

8. The first major investment in agriculture was made by Australia which, in cooperation with International Rice Research Institute (IRRI), established a substantial research facility under the Cambodia-Australia IRRI Project (CAIP). This eventually became the Cambodia Agricultural Research and Development Institute (CARDI) in 1999. With this strong national research input, many new varieties of rice were released but there was no organized seed system to commercialize these varieties and supply improved seed to farmers and other stakeholders. To fill this gap in the seed chain, AusAID launched the Agricultural Quality Improvement Project (AQIP) in 1997 with seed production and distribution as a major component. Initially four regional seed companies were established but at the time of project closure in 2007 these were merged into a single 'AQIP Seed Co'. This is still the only integrated national seed company and it deals only in rice seed.

9. Over the past twenty years, projects by governmental and non-governmental organizations have supported local and community-based initiatives in different provinces with the emphasis on seed production groups and farmer training on seed production, mostly for rice. Some of these have done good work during implementation but they often lacked a sound financial or marketing plan and were not sustainable after project closure. However, despite these many useful interventions, and much experienced gained, the seed sector remains uncoordinated and is not in a strong position to move to a more commercial model. Making this transition is a key element in the strategy of the Government for strengthening agricultural production generally and increasing the export of high quality milled rice.

10. Many other crop seeds, notably of maize and vegetables, are mostly imported from Vietnam, Thailand or other countries where there are well-established private companies with their own breeding programs. In the short term, it is difficult for Cambodia to produce and supply these seeds to the same quality standards. For these crops, emphasis should be placed on strengthening a more organized system for testing and registering

varieties that are useful for farmers and at the same time strengthen local varietal development and seed production and distribution.

## 1.2 Key Constraints and Challenges for the Seed Industry

11. Consultations with a wide range of stakeholders in the preparation of this policy have identified several key constraints that limit the development of a more effective seed industry including:

- Inadequate dissemination of technical information and poor awareness of the value and advantages of using good quality seed,
- Seed quality standards and a certification system have not yet been developed or implemented,
- Lack of transparency in import and registration procedures, leading to a large informal trade with little information about the quality of the imported materials;

And in the specific context of rice seed....

- ✓ Difficulty of planning seed production due to uncertain demand from farmers and the market,
- ✓ Limited awareness about varieties and market requirements leading to milled rice being sold as "mixed varieties" at a low market price,
- ✓ Lack of clear differentiation between paddy rice and seed, so farmers are reluctant to pay a premium price for seed,
- ✓ Insufficient benefit from using quality seed due to weaknesses in the value chain after harvest.

12. One fundamental problem faced by the seed industry in Cambodia is that the production and marketing of rice seed is a relatively unprofitable activity and therefore unattractive for private investors, despite the importance of quality seed as an input. Investments in large-scale seed production by the public sector to address this problem are difficult to manage and often become a financial burden. The key challenge for rice seed, is to organize the supply system in a way that meets farmers and other stakeholders needs but is sustainable without the need for continuing subsidies.

13. The seeds of other crops, especially hybrid maize, are more profitable and are normally taken care of by the private sector. However, each crop or group of crops, has its own specific problems in the organization of seed supply, or of planting material in the case of crops that are not propagated by seed. Through better consultation and coordination between technical specialists and stakeholders, this policy aims to address these needs so all farmers and farming systems can have access to good varieties and quality seeds.

14. It is clear from the above analysis that the seed industry in Cambodia is still at an early stage of development and needs further support and investment. However, the

constraints outlined above are not primarily technical; they relate mostly to matters of finance, organization and the institutional framework. These are issues that can be addressed by policy actions and with the support of the law on some specific aspects relating to varieties and seed quality.

## 2. VISION, GOAL AND OBJECTIVES

### 2.1 Vision

15. An efficient and sustainable seed industry that meets the needs of farmers and other stakeholders both for domestic food security and provides a surplus of high quality and safe agricultural products for export, thus contributing to the improvement of rural livelihoods and national economic growth.

### 2.2 Goal

16. To ensure that farmers and other stakeholders have access to high quality seeds and a wide range of improved varieties through the most reliable and economic supply channels so that the productive potential of the land, and of farmers, can be fully realized.

### 2.3 Objectives

17. To achieve this vision and goal, this policy has the following objectives:

- improve the effectiveness of seed sector institutions and systems (at all levels) with good management and coordination through stronger linkages among all the stakeholders;
- establish official controls and procedures for seeds and varieties in line with those in other countries of the region to facilitate trade and integration in the ASEAN community;
- strengthen responsibilities on the development of seed industry between the public and private sectors;
- increase farmers' awareness about the benefits of using improved varieties and good quality seed through extension campaigns and demonstrations;
- strengthen the capacity of rice seed producer groups to respond to local needs and the requirements of the export market;
- develop regulations and procedures for certification and inspection to ensure that seed with good quality is widely available to growers
- promote investment from public institutions and private sector to strengthen the seed sector in a sustainable and effective way.

## 3. STRATEGY

18. Development of crop seeds is based on a well-integrated and connected mechanism with five key players, namely researchers, producers, traders, inspectors and users. This mechanism mainly depends on the management structure and organization, laws and

regulations, technical guidelines and financial management. To achieve the goal of sustainable development of seed industry the following strategies will be pursued:

### 3.1 Management of the Seed Sector

19. The Law on Seed Management and Plant Breeders' Rights (2008) provides the legal basis for regulating the seed sector and GDA is the executive body responsible for implementing the regulations (Prakas) made under that law. To ensure good coordination between the different crops, GDA will establish a **Seed Management Unit (SMU)** that will manage the regulatory functions and act as a focal point for all activities and information related to seeds and planting materials.

20. The seed management includes a series of activities that begin with research, development, release of varieties and seed production until the usage for cultivation in fields. Many different stakeholders participate directly in this chain depending on its outputs and there should be a coordination mechanism to bring these different interests together. For this purpose, MAFF will establish a **National Seed Council (NSC)** to oversee and monitor the development of the seed sector in accordance with this policy. The status, membership and functions of this NSC is determined in a Prakas issued by the MAFF. The SMU of GDA will provide the secretariat for the Council.

21. Investments by development partners that support the seed sector are welcome and shall be implemented in harmony with this policy and other strategic plans of the Government. To ensure good coordination, all official development projects, companies, associations and non-governmental organizations that engage in seed production or supply shall provide a brief annual report on their activities to the SMU.

### 3.2 Variety Development

22. Breeding improved varieties is essential for maintaining and increasing agricultural productivity, particularly to address the needs of diverse markets and to increase climate resilience. Much of this work is conducted by public institutions and where appropriate, in partnership with the relevant international agricultural research institutes. However, private companies and other organizations are also encouraged to undertake plant breeding and selection to increase the choice of varieties available to farmers and other stakeholders. The introduction of Plant Variety Protection will be an incentive to private investment, as noted in next section of this policy.

23. CARDI is the main agricultural research institution that has implemented variety improvement programs in rice and some other crops. Development partners are encouraged to participate in these programs with matching funds for an agreed time frame and subject to a regular external review of progress. More attention will be given to breeding climate resilient varieties and addressing specific market requirements.

24. Companies or their local agents are encouraged to conduct trials of new varieties in

the main production areas or in the research stations of the Provincial Departments of Agriculture, Forestry and Fisheries (PDAFF). Varieties of rice and other field crops imported for trials shall be notified to the SMU so that technical staff can inspect during the growing season if necessary. The importation of seeds for trial purposes prior to registration shall be facilitated, up to a quantity specified for each crop.

